D59683

TSL

Y 59

— Yim Duong [illegible]

[illegible]

[illegible]

1-11-78 ចាប់

29 ans

ខ្ញុំសូមរាយការជូនបក្ស

អំពីប្រវត្តិសកម្មភាពសេ.អ៊ី.អារបស់ខ្ញុំប្រឆាំងបក្ស

---

ខ្ញុំឈ្មោះឃួន.ឈួង អាយុ២៩ឆ្នាំ ភេទប្រុសមានគ្រួសារហើយ ។ ស្រុកកំណើតខ្ញុំនៅភូមិរើល ឃុំដូនតី ស្រុកពញាក្រែក តំបន់២០ ភូមិភាគបូព៌ា ។

.ឪពុកខ្ញុំឈ្មោះឃិន.គឹម ស្លាប់តាំងពីខ្ញុំនៅតូច និងម្តាយឈ្មោះយ៉ាន បច្ចុប្បន្នមិនដឹងអង្គការជុំលៀសទៅនៅឯណាទេ ។

ខ្ញុំមានបងម្នាក់ និងប្អូនម្នាក់ :

១.បងឈ្មោះ ឃិន.ទៀង ពីមុនធ្វើទាហាននៅក្រុង[illegible] ព្រៃវែង - កាលឆ្នាំ ៧៥ក្រោយរំដោះហើយគាត់ឈប់ធ្វើទាហាន មកចូលធ្វើជាពួកក្រុមក្បាលស តែក្រោយមកបែកមុកក៏អង្គការកំទេចចោលទៅ ។

២-ប្អូនឈ្មោះ ឃិន.ហេង ក្រោយរំដោះឆ្នាំ ១៩៧៥អង្គការបានរើសយកទៅឱ្យធ្វើជាកម្មករនៅក្នុងរោងចក្រភ្នំពេញតែខ្ញុំមិនដឹងរោងចក្រណាទេ ។

អំពីសកម្មភាពសេ.អ៊ី.អារបស់ខ្ញុំផ្ទាល់

---

តាំងពីតូចមកខ្ញុំរស់នៅជាមួយឪពុកម្តាយខ្ញុំរហូតមកដល់ឆ្នាំ ១៩៧០ ក្រោយពេលថ្ងៃរដ្ឋប្រហារ ។

ក្នុងពាក់កណ្តាលឆ្នាំ ១៩៧០ ខ្ញុំចូលធ្វើបដិវត្តមកនៅក្នុងឈ្លបភូមិរើល ឃុំ ដូនតី ។ ក្រោយមកឈ្មោះ សំបូប្រធានពេទ្យតំបន់២០ មកបោះមន្ទីរពេទ្យនៅជិតផ្ទះរបស់ខ្ញុំ - ហើយគាត់ឧស្សាហ៍មកលេងនៅផ្ទះរបស់ខ្ញុំជាមួយបងស៊ឹម កាលនោះបងស៊ឹមខ្ញុំមិនទាន់ដឹងនាទី

នត់ទេ តែក្រោយមកគាត់នាទីជាលេខាស្រុកពញាក្រែក បច្ចុប្បន្នគាត់រត់ចូលទៅអណ្តូងព្រីងខាងកើតភូមិតាថែ ឃុំកក់ ស្រុកពញាក្រែក ឯបងសំបូ បច្ចុប្បន្នចាប់ហើយ ហើយបានមកអប់រំខ្ញុំជាបន្តបន្ទាប់ ដោយលើកឱ្យខ្ញុំឃើញពីរបបឯកជនសប្បាយ ចង់ធ្វើអីក៏បាន មិនដូចរបបបដិវត្តទេ គឺរបបបដិវត្តតឹងតែងខ្លាំងណាស់ ហើយគេឲ្យ ទាំងការដើរហើរក៏មានការសុំ ឬទាល់តែមានការអនុញ្ញាតពីអង្គការទើបដើរបាន ឯការលេងសើចក៏តឹងតែងដែរ បើលេងសើចខុសបន្តិចបន្តួចក៏គេកសាងដែរ និយាយរួមស្តីក៏តឹងទាំងអស់ ឥឡូវនេះយើងឃើញបញ្ហា ចាំមើលបន្តិចទៀតយើងកាន់តែជួបការលំបាកផាងនេះ-ថែមទៀត ។ ហើយថែមទាំងគ្មានសិទ្ធិសេរីភាពថែមទៀតផង ។ ងខាងពុទ្ធសាសនាក៏បដិវត្តបំបាត់ចោលអស់ដែរ ។ ដូច្នេះប្អូនបើធ្វើជាមួយបងប្អូនឯងមានសិទ្ធិសេរីភាពឡើងវិញ មានមុខមាត់ មានបុណ្យសក្តិ មានកិត្តិយស មានការសប្បាយចង់យើងធ្វើអីកបានដែរ មិនដូចរបបបដិវត្តនេះទេ ដូច្នេះយើងធ្វើជាខ្មែរ-មួយដើម្បីរួមគ្នាជាកំលាំង ហើយយើងធ្វើការតស៊ូមួយដោយយើងបង្កប់នៅក្នុងបដិវត្តមួយ-រយៈ ដល់ពេលយើងមានកំលាំងយើងធំហើយគឺយើងរួមគ្នាវ៉ៃបដិវត្តតែម្តង ។

--.ជាមួយនេះខ្ញុំមានជំនឿទៅលើការអប់រំរបស់គាត់ យើងខ្ញុំប្រាប់គាត់វិញថា បងនិយាយនេះត្រឹមត្រូវមែន ដូច្នេះបើបងឱ្យខ្ញុំធ្វើអីកខ្ញុំធ្វើដែរ ។ ជាមួយនេះបងសំបូនិយាយទៀតថា : បើអីចឹងប្អូនឯងត្រូវចូលធ្វើជាខ្មែរសេ.អ៊ី.អាជាមួយបងទៅហើយ បញ្ហានេះយើងត្រូវយកចិត្តទុកដាក់ល័ក្ខឱ្យបានទោះជាបងប្អូនឬឪពុកម្តាយយើងក៏ដោយ ក៏យើងមិនត្រូវឱ្យគាត់ដឹងទាំងអស់ ហើយត្រូវតែដាច់ខាតបំរើខ្មែរយើងឱ្យបាន ទោះជាយើងត្រូវស្លាប់ក៏ដោយ ឬជួបការលំបាកយ៉ាងណាក៏ដោយ

យើងត្រូវហ៊ានពុះពា ធ្វើពលីកម្មគ្រប់បែបយ៉ាងដើម្បីយើងសំរេចផែនការរបស់ខ្មែរយើងឱ្យបាន ហើយយើងត្រូវតែប្រឆាំងនិងបដិវត្តឱ្យដាច់ខាត តែយើងត្រូវតែលីក្ខាការឱ្យបានដាច់ខាតដើម្បីយើងបង្កប់នៅក្នុងបដិវត្ត បំផ្លាញបដិវត្តមិនឱ្យរីកចំរើនបាន ។ ដូច្នេះក្រោយពីមិត្តឯងចូលជាខ្មែរស.អ៊ី.អា ហើយមិត្តឯងត្រូវទាក់ទងខ្មែររបស់យើងមួយចំនួនទៀតដើម្បីយើងរួមសកម្មភាពគ្នាឱ្យបានខ្លាំងក្លា និងដើម្បីធ្វើកុំឱ្យបដិវត្តរីកចំរើនតទៅមុខទៀតបាន ។

១. ឈ្មោះ ឡាង សមាជិកឃុំដូនតី បច្ចុប្បន្នអង្គការចាប់ហើយ ។

២-ដៀប ប្រធានសហករភូមិពាមរាក់ បច្ចុប្បន្នចាប់ហើយ ។

៣-សេង ប្រធានភូមិពាមស្វាយ បច្ចុប្បន្នចប់ហើយ ។

៤-ហឿង សមាជិកឃុំឧត្តមានជ័យ បច្ចុប្បន្នចាប់ហើយ ។

៥. ប៉េង ប្រធានភូមិបែកក្អម ឃុំឧត្តមានជ័យ បច្ចុប្បន្នក្នាប់មិនបាន ។

ក្រោយពីបង សំបូ និងបងស៊ុម បានណែនាំខ្ញុំហើយមក ដល់ក្រោយពីនេះមកខ្ញុំបានមករួមសកម្មភាពជាមួយបង ឡាង និងបង ដៀប និងបង សេង និងបងហឿង និងបងប៉េង បំផុសប្រជាជនឱ្យប្រឆាំងនិងកំលាំងធំរបស់អង្គការ គឺប្រឆាំងនិងក្រុមប្រវ៉ះដៃដែលក្រុមសាមគ្គីរួមជាកំឡាំងសមូហភាពបណ្តើរពុះទៅសមូហភាពកាន់តែធំកាន់តែខ្លាំង[illegible] និងបំផុសមិនឱ្យប្រជាជនមានជំនឿទេលើអង្គការបដិវត្ត ដោយលើកថាអង្គការបំ-បិតពុទ្ធសាសនា បំបិតមិនឱ្យមានលោក និងវត្តអារាម និងបំផុសឱ្យប្រជាជនមើលឃើញថាបដិវត្តគៀបប្រជាជន មិនឱ្យប្រជាជនដើរហើរបានតាមចិត្តទេ គឺតឹងតែងបើ-ប្រជាជនណាចង់ដើរហើរគឺទាល់តែសុំ ទាល់តែមានការអនុញ្ញាតិពីអង្គការទៀត ។

-. ដល់ដើមឆ្នាំ ១៩៧១ . ខ្ញុំបានមករួមសកម្មភាពជាមួយឈ្មោះ ហឿង និងបងដៀប ហើយខ្ញុំបានរួមសកម្មភាពជាមួយគាត់បំផុសប្រជាជនឱ្យប្រឆាំងនិងរបបបដិវត្ត-ដោយលើកថា ធ្វើបដិវត្តលំបាកគ្មានសិទ្ធិសេរីភាព ការដើរហើកលំបាកមិនដូចពីសង្គមដែលយើងរស់នៅមានស្ដេចទេ គឺស្ដេចទំាលបញ្ញាយដាងរបបបដិវត្ត ។

-.ការទាក់ទងខ្មែររបស់ខ្ញុំនៅខាងលើនេះគឺខ្ញុំបានទាក់ទងធ្វើសកម្មភាពនេះដាប់រហូតមកដល់ឆ្នាំ ១៩៧២ ។

-. ដល់ឆ្នាំ១៩៧២ . បងឡាង បានចាត់តាំងខ្ញុំមកឱ្យចូលបង្កប់នៅក្នុងកងទ័ពស្រុកពញាក្រែក តំបន់២០ ។ ពេលដែលខ្ញុំមកនេះគឺបងឡាង បានឱ្យខ្ញុំមកទាក់ទងខ្មែរសេ.អ៊ី.អា របស់គាត់នៅក្នុងស្រុក និងនៅក្នុងកងទ័ពស្រុកពញាក្រែកមួយចំនួនមានឈ្មោះ

១-ស៊ុម លេខាស្រុកពញាក្រែក ។

២-ភុន អនុប្រធានឃោសនាការស្រុក បច្ចុប្បន្នចាប់ហើយ ។

៣.សាលី ជំនួយការស្រុកពញាក្រែក បច្ចុប្បន្នចាប់ហើយ ។

៤-ផល់ ប្រធានរោងពុម្ពស្រុក បច្ចុប្បន្នចាប់ហើយ ។

-. ក្រោយពេលដែលខ្ញុំមកដល់ស្រុកហើយខ្ញុំបានមកជួបជាមួយបងស៊ុម ហើយបងស៊ុមបានហៅខ្ញុំទៅណែនាំថា មិត្តឯងមកនៅក្នុងខី ស្រុកហើយមិត្តឯងត្រូវដាច់ការទាក់ទងខ្មែរយើងនៅខាងភូមិឃុំហើយ តែមិត្តឯងមកនៅក្នុងស្រុកនេះមិត្តឯងត្រូវទាក់ទងខ្មែរយើងនៅស្រុកធ្វើសកម្មភាពរបស់យើងបន្តទៅទៀតគឺមានឈ្មោះ .

១-សារ៉ន ប្រធានឃោធាស្រុកពញាក្រែក បច្ចុប្បន្នចាប់ហើយ។

២-បូ ប្រធានទ័ពស្រុកពញាក្រែក បច្ចុប្បន្នចាប់ហើយ ។

៣-ឡាត់ ប្រធានគ ក្រោយពេលដែលផ្ទុះអាវុធខ្ញុំភ្លាប់មិនបាន ។

៤.សន ប្រធានទ័ពស្រុក បច្ចុប្បន្នរត់ទៅនៅព្រៃជាមួយខ្ញុំ ។

៥.ស៊ិន អនុក្រុម បច្ចុប្បន្ននៅជាមួយខ្ញុំក្នុងព្រៃដែរ ។

៦.ថៃ ប្រធានក្រុម ក្រោយសភាពការណ៍ខ្ញុំភ្ជាប់មិនបាន ។

៧.ថេង ប្រធានខ ក្រោយសភាពការណ៍ខ្ញុំភ្ជាប់មិនបាន ។

៨.សំ អនុគ ការវ៉ៃយួនស្លាប់ហើយ ។

៩.សាយ ប្រធានខ ក្រោយយួនវ៉ៃខ្ញុំភ្ជាប់មិនបានទេ ។

១០.ស៊ាងហេង និរសាបងសារ៉េន បច្ចុប្បន្នអនុប្រធានគ ចោរព្រៃ ។

-. ក្រោយពីខ្ញុំមកនៅក្នុងយោធាស្រុកហើយបងសារ៉េនបានឱ្យខ្ញុំមកកសាងកំលាំង-ស.អី.អា ថែមទៀត ។

ក្រោយពីគាត់ណែនាំខ្ញុំហើយមកខ្ញុំបានធ្វើការកសាងកំលាំង ស.អ៊ី.អា បានមួយចំនួនមាន-

១.យ៉ុន យុទ្ធជន ក្រោយមកប្រធានខ បច្ចុប្បន្នជាយុទ្ធជនចោរ ។

២.សាម៉ា យុទ្ធជន បច្ចុប្បន្នងាប់ហើយ ។

៣.សង្ហា យុទ្ធជន បច្ចុប្បន្នងាប់ហើយ ។

ចំពោះអ្នកទាំងអស់នេះខ្ញុំអប់រំដោយលើកពីរបបសង្គមចាស់ និងលើកពីការធ្វើបដិវត្តមានការលំបាក គ្មានការសប្បាយ គ្មានសិទ្ធិសេរីភាព និងតឹងតែងគ្រប់បែបយ៉ាង ។ ហើយធ្វើបដិវត្តគ្មានបុណ្យសក្តិ គ្មានប្រាក់ខែដូចកាលពីសង្គមចាស់ទេ ។

ក្រោយពីខ្ញុំអប់រំអ្នកទាំងបីនាក់នេះបាន ហើយខ្ញុំក៏យកមករាយការណ៍ឱ្យបងស៊ុំទទួលស្គាល់ ។

-.ដល់ឆ្នាំ ១៩៧៣ បងសារ៉េនបានចាត់តាំងខ្ញុំមកទទួលជាកម្មាភិបាលអប់រំឈ្លបរបស់ស្រុកពញាក្រែក ។

ក្រៅពីនេះទៀតខ្ញុំបានរួមជាមួយខ្សែរបស់ខ្ញុំបំផុសយុទ្ធជនពីរបបសង្គមចាស់មានការសប្បាយ

និង លើកទៀតឱ្យយុទ្ធជន ឃើញថា របបបដិវត្តមានការតឹងតែង ធ្វើអ្វីៗ ដើរក៏មិនបានដែរ ។ ចំពោះសកម្មភាពរបស់ខ្ញុំនិងខ្មែរខ្ញុំនៅខាងលើនេះបានអនុវត្តន៍ជាបន្តបន្ទាប់រហូតមកដល់ឆ្នាំ ១៩៧៥ ។

-. ក្រោយរំដោះថ្ងៃ ១៧ មេសា ១៩៧៥ បងសារ៉ន បានឱ្យខ្ញុំមកទាក់ទងខ្មែរស. អុី.អា របស់គាត់មួយចំនួនមានឈ្មោះ .

| | | | |
|---|---|---|---|
| ១.ឃួស | ប្រធានឃុំឧត្តមានជ័យ | បច្ចុប្បន្នចាប់ហើយ | ។ |
| ២.ហ៊ាន | អនុឃុំឧត្តមានជ័យ | បច្ចុប្បន្នចាប់ហើយ | ។ |
| ៣.ដួន | ប្រធានឃុំដូនតីខាងលិច | បច្ចុប្បន្នចាប់ហើយ | ។ |
| ៤.ម៉ុន | អនុ ឃុំដូនតីខាងលិច | បច្ចុប្បន្នចាប់ហើយ | ។ |
| ៥.សៅ | ប្រធានឃុំដូនតីខាងកើត | បច្ចុប្បន្នចាប់ហើយ | ។ |
| ៦.យាន | អនុឃុំដូនតីខាងកើត | បច្ចុប្បន្នចាប់ហើយ | ។ |
| ៧.ម៉ែអម [illegible] | សមាជិកឃុំដូនតីខាងកើត | បច្ចុប្បន្នចាប់ហើយ | ។ |

ក្រោយពីគាត់បានណែនាំខ្ញុំហើយ បក្ខពួកខ្ញុំបានមកទាក់ទងខ្មែរខ្ញុំទាំងបីឃុំ ហើយរួមធ្វើសកម្មភាពបំផុសកងឈ្លប នៅតាមឃុំទាំងបីឱ្យស្រើបស្រាលស្រឡាញ់របបសង្គមចាស់ឱ្យស្អប់របបបដិវត្ត ដោយលើកពីការធ្វើបដិវត្តមានការលំបាកតឹងតែង ធ្វើការងាររកពេលសម្រាកគ្មានបើ ចង់ធ្វើអ្វីក៏មិនបានដែរ ទៅណាក៏ទាល់តែមានការអនុញ្ញាតិពីគេទើបធ្វើបាន ចង់ហូបអ្វីឯកជនក៏មិនបានដែរ ។ តែបើធ្វើការងាររបស់សង្គមចាស់យើងមានប្រាក់ខែចាយវាយនិង ធ្វើអ្វីបានតាមចិត្ត ហើយចង់ដើរហើរទៅណាក៏បានដែរ ។

-. ដល់ខែ ៥ ឆ្នាំ ១៩៧៥ បងសារ៉ន បានហៅខ្ញុំ និងសាម៉ា . និង សង្ហា និងសារ៉ាត និងយ៉ុន ទៅប្រជុំផែនការ ពេលប្រជុំនេះគឺគាត់ឱ្យពួកខ្ញុំដែលទៅចូលរួមប្រជុំនេះទៅ

ទាក់ទងប្អូន ហើយយកស្រូវរបស់អង្គភាពយោធាស្រុកទៅឱ្យប្អូនអស់ចំនួន ១២បាវ ដែលយោធាស្រុកធ្វើបាននៅជិតព្រំដែន គឺឱ្យប្អូនឈ្មោះថញ៉ា និងដើម្បីលាកាជាមួយប្អូនឱ្យជាប់ត្រៀមផែនការទទើបកទ្រុកក្ដួយនិសកម្ពុជា នៅពេលក្រោយ អាថាញ៉ានេះ -ជាសេដ្ឋកិច្ចរបស់យោធាតំបន់តែនិញ ។

តែនៅក្នុងការដែលយកស្រូវទៅឱ្យប្អូននេះពួកខ្ញុំធ្វើជាដូរខ្លះដើម្បីបំបិតភ្នែកមហាជនកុំឱ្យដឹងពីផែនការរបស់ខ្មែរខ្ញុំ ។

-. ក្រៅពីនេះពេលដែលខ្ញុំមានភារៈកិច្ចទៅរើសកងឈ្លបឃុំមកឱ្យធ្វើកងទ័ពរបស់ភូមិភាគបូព៌ា ពេលនោះខ្ញុំបានធ្វើសកម្មភាពសំឡុតគំរាមកំហែងប្រជាជន ហើយជេរប្រជាជនថាសុទ្ធតែមីកញ្ជាស់ អាកញ្ជាស់ទុកកូនធ្វើអី ឬទុកឱ្យគិតមិនព្រមឱ្យទៅធ្វើយោធា ។ ចំពោះសកម្មភាពរបស់ខ្ញុំនេះធ្វើឱ្យប្រជាជនខឹងនិងបដិវត្ត ដោយខ្ញុំសំឡុតគាត់ហើយខ្ញុំលើកថាទិសរបស់អង្គការឱ្យយុទ្ធជនឱ្យទៅធ្វើយោធា ។

ចំពោះការធ្វើសកម្មភាពទាំងអស់នេះ ធ្វើឱ្យប្រជាជនខឹង និងប៉ះពាល់ដល់ស័ក្ដារបស់ខ្មែរស.អ៊ី.អា របស់ខ្ញុំខ្លាំងពេកក៏បងសារ៉ន ចាត់តាំងខ្ញុំមកទទួលជាសមាជិកទី១ខាងផលិតកម្មស្រុកពញាក្រែក ។

-. ខែ៤ ឆ្នាំ ១៩៧៦ ពេលដែលខ្ញុំមកឈ្មោះឡាងជាខ្មែររបស់ខ្ញុំពេលនោះឈ្មោះឡាងបានឱ្យខ្ញុំទាក់ទងខ្មែររបស់គាត់នៅក្នុងភូមិមួយចំនួនទៀតមានឈ្មោះ :

១. ផាន សមាជិកគណៈសហករភូមិទួល ឃុំដូនតីខាងលិច បច្ចុប្បន្នជាសមាជិកទី៤ ឃុំដូនតីខាងលិច ។

២ -ជា ប្រធានភូមិទួលឃុំដូនតីខាងលិច បច្ចុប្បន្នប្រជាជនភូមិទួល។

៣.ឯន សមាជិកភូមិទី១ទ្រៃពអង្គរក្នុង បច្ចុប្បន្នប្រធានមុកព្រួញា
ប្រចួតភូមិទ្រៃពអង្គរក្នុង ឃុំដូនតីខាងលិច ៗ

៤.ឆាយ ប្រធានសហករភូមិទ្រៃពអង្គរក្នុងបច្ចុប្បន្នប្រធានមុកព្រួ-
ញាប្រចួតភូមិពានទ្រៃពឃុំកណ្ដោជ្រុំស្រុកពញ្ញាក្រែក ៗ

៥.ស៊ុយ អនុប្រធានភូមិទ្រៃពអង្គរក្នុង បច្ចុប្បន្នប្រជាជនភូមិទ្រៃព
អង្គរក្នុង ឃុំដូនតីខាងលិច ស្រុកពញ្ញាក្រែក ៗ

៦.យ៉ាំ សមាជិកសហករភូមិពរទាង បច្ចុប្បន្នប្រជាជនភូមិពរទាង

៧.សយ ប្រធានឈ្លបភូមិពរទាង បច្ចុប្បន្នប្រធានមុកព្រួញាភូមិ-
ពរទាង ឃុំដូនតីខាងលិច ស្រុកពញ្ញាក្រែក ៗ

៨.យ៉ាន ប្រធានឈ្លបភូមិពានទ្រៃជ បច្ចុប្បន្នប្រធានមុកព្រួញាប្រចួត
ភូមិពានទ្រៃជ ឃុំកណ្ដោជ្រុំ ស្រុកពញ្ញាក្រែក ៗ

៩. ទូច ប្រធានឃ្លាំងសហករភូមិពានទ្រៃជ បច្ចុប្បន្នប្រធានឈ្លបសហ
ករភូមិពាទ្រៃជ ៗ

១០.ស៊ុន ប្រធានឈ្លបឃុំកណ្ដោជ្រុំ បច្ចុប្បន្នប្រជាជនភូមិសុវណ្ណគុម ៗ

១១.ទុំអ ប្រធានឈ្លបភូមិបុសខ្នារ បច្ចុប្បន្នប្រធានខាងដាំបាយ -
សហករភូមិបុសខ្នារ ឃុំកណ្ដោរជ្រុំ ស្រុកពញ្ញាក្រែក ៗ

១២.ចយ ប្រធានឈ្លបភូមិបុសខ្នារ បច្ចុប្បន្នប្រជាជនភូមិបុសខ្នា ៗ

ដើម្បីរួមសកម្មភាពគ្នា នៅក្នុងមូលដ្ឋាន ៗ

ក្រោយពីប្រាប់ហើយខ្ញុំនិងបងទ្បាង និង សមា៉ និងសង្ហា និង យ៉ន បានមកធ្វើសកម្មភាព

*បំផុសប្រមាថដែរ ធ្វើសកម្មភាពពីលើកម្មនៃ ។*

-.ដល់ចុងឆ្នាំ ១៩៧៦ បងស៊ីម និងបងសារ៉ន បានហៅខ្ញុំនិងខែ្មរទៅចាត់តាំងឱ្យ យកស្រូវ ១២បាវ និង ជ្រូក និងមាន់ទា មួយចំនួនទៅឱ្យប្អូនឈ្មោះ អាថាញ់ម្តងទៀត អ្នកដែលទៅជាមួយខ្ញុំពេលនោះមានឈ្មោះសារ៉ាត និងសាម៉ា និងយ៉ុន និងសង្ហា ។ ដល់ពេលចេញទៅគឺបងសារ៉នគាត់រៀបចំផ្លូវចេញ ដោយដកកងទ័ពស្រុកចេញពីមុខដែលទៅទាក់ទងប្អូន ។

-. ដល់ឆ្នាំ ១៩៧៧ ខ្ញុំត្រូវបងស៊ីមចាត់តាំងឱ្យធ្វើជាប្រធាន១ កងស្រុកពញាក្រែក រួចហើយគាត់ឱ្យខ្ញុំមកការពារមុខសញ្ញាភូមិត្នោតតាមព្រំដែន ។

-.ពេលដែលទៅត្រៀមនោះខែ្មរខ្ញុំមានឈ្មោះ យ៉ុន និង សង្ហា តាមផែនការរបស់បងសារ៉ន ឱ្យខ្ញុំនិងខែ្មរទៅបាញ់ប្អូនដែលពីចំងាយហើយឱ្យដករត់ចោលសមរភូមិ ។

-.ដល់ចុងឆ្នាំ ១៩៧៧ បងសារ៉ន បានឱ្យខ្ញុំ និងសង្ហា និងយ៉ុន បំផុសយុទ្ធជនឱ្យរត់ចោលសមរភូមិដើម្បីឱ្យប្អូនបុកចូល និងដើម្បីរួមផែនការសហការជាមួយប្អូនរើបក្សកុម្មុយនិសកម្ពុជា ដែលជាផែនការធ្វើរដ្ឋប្រហារ ។ តែក្នុងការបំផុសនេះគឺលើកឡើងថាខ្មាំងពីទពីខាងក្រោយ បើនៅស្លាប់ហើយ ។

ពេលនោះដែរខ្ញុំក៏ត្រូវរបួសមកដេកពេទ្យរបស់តំបន់២០ ។ ពេលដែលខ្ញុំមកដេកពេទ្យអស់រយៈពេល២ខែនោះខ្ញុំបានទាក់ទងជាប់ខែ្មរជាមួយឈ្មោះ អំា ប្រធាន១ កងទ័ពតំបន់ ២០ បច្ចុប្បន្ននៅធ្វើសេដ្ឋកិច្ចដាំបាយរបស់សហករភូមិពរោង ឃុំដូនតីខាងលិចៗ ក្រោយមកបានពីខែខ្ញុំត្រូវចេញពីពេទ្យមកអង្គភាពវិញ ។

ពេលដែលខ្ញុំមកនៅក្នុងអង្គភាពវិញបងសារ៉ន បានឱ្យខ្ញុំមកនៅកន្លែងសេដ្ឋកិច្ចវិញ - ព្រោះខ្ញុំរបួសនោះត្រូវខូចដៃស្តាំមួយ ។

ហើយគាត់បានឱ្យខ្ញុំមកទាក់ទងខ្មែរគាត់នៅកន្លែងសេដ្ឋកិច្ចពីនាក់ទៀតមានឈ្មោះនាំ ប្រធានសេដ្ឋកិច្ចយោធាស្រុកពញាក្រែកបច្ចុប្បន្នអង្គការឱ្យទៅធ្វើស្រែនៅឃុំ - កណ្ដាជ្រុំ ស្រុកពញាក្រែក តំបន់ ២០ ។

ទី២ ឈ្មោះ ផន អនុសេដ្ឋកិច្ចយោធាស្រុកពញាក្រែក តំបន់ ២០ ។ បច្ចុប្បន្នអង្គការឱ្យទៅធ្វើស្រែនៅក្នុងឃុំ កណ្ដាជ្រុំ ស្រុកពញាក្រែក តំបន់ ២០ ។

ហើយពេលដែលខ្ញុំមកនៅក្នុងផ្នែកសេដ្ឋកិច្ចនេះបងសារ៉េនបានឱ្យខ្ញុំធ្វើសកម្មភាព ដកហូបយុទ្ធជនមិនឱ្យហូបគ្រប់គ្រាន់ គឺក្នុងម្នាក់ឱ្យហូបតែមួយកំប៉ុងក្នុងមួយថ្ងៃ ។ហើយបើម្ហូបវិញ គឺគាត់បានឱ្យខ្ញុំដាក់អំបិលឱ្យយុទ្ធជនហូប ដើម្បីកុំឱ្យយុទ្ធជនមានកំលាំងប្រយុទ្ធ និងស្រួលដល់ខ្មែរដែលនៅត្រៀមជាមួយយុទ្ធជនបំផុសឱ្យយុទ្ធជនរត់ចោលខ្មែរត្រៀម ដើម្បីរួមសម្រេចផែនការដែលខ្មែរដឹកនាំលើកឡើង ។

ក្រោយពីបងសារ៉េនណែនាំ ហើយខ្ញុំបានមករួមសកម្មភាពជាមួយឈ្មោះ ផន និងឈ្មោះ នាំ ធ្វើសកម្មភាពជាមួយគាត់ដកហូបយុទ្ធជនតាមផែនការដែលគាត់ណែនាំខ្ញុំជាបន្តបន្ទាប់ - រហូតមក ។

ក្នុងខែ១១ ឆ្នាំ ១៩៧៨ខ្ញុំបានទាក់ទងជាប់ខ្មែរជាមួយឈ្មោះ ស៊ិន អនុគយោធាតំបន់២០ - ក្នុងពេលដែលអង្គភាពយោធាស្រុក និងអង្គភាពយោធាតំបន់២០ សហការការពារនៅ តាមព្រំដែន ។បច្ចុប្បន្នស៊ិន ជាប្រធានគ ពួកចោរព្រៃអណ្ដូងព្រីង ។

ក្រៅពីនេះខ្ញុំបានធ្វើសកម្មភាពតាមផែនការដែលបងសារ៉េនណែនាំ រហូតមកដល់ក្រោយសភាពការខ្ញុំក៏រត់មកនៅផ្ទះវិញ ។

ពេលនោះអង្គការបានចាប់ខ្មែរខ្ញុំមួយចំនួនជាថ្នាក់ ឃុំ និងស្រុក ។
ក្រោយមកនៅក្នុងខែ៧ ឆ្នាំ ១៩៧៨ ឈ្មោះស៊ិនអនុគហោធាតំបន់២០បានមកជួបខ្ញុំនៅក្នុងផ្ទះរបស់ខ្ញុំហើយគាត់និយាយថា សភាពការឥឡូវនេះមិនស្រួលទេព្រោះយុទ្ធជន ក្ដីនិងអ្នកដែលមាននាទីដូចយើងក៏គេមិនទុកដែរគឺចាប់យកទៅសម្លាប់ចោលទាំងអស់ដូច្នេះមិត្តឯងនៅផ្ទះត្រូវប្រយ័ត្នឱ្យមែនទែន ។ដែលសំខាន់ជាទិសរបស់យើង គឺមានតែ-មួយទេគឺយើងរត់ចូលព្រៃ ទើបយើងបានរស់ហើយយើងត្រូវខំរក្សាឱ្យបានថែមទៀតកុំឱ្យបែកការទៅណាឱ្យសោះ ។
ក្រោយពីនិយាយគ្នាដល់ត្រឹមនេះគាត់ក៏លាខ្ញុំទៅផ្ទះគាត់វិញទៅ ហើយថាប្រាប់ខ្ញុំ ថាចាំថ្ងៃក្រោយចាំគាត់មកជួបខ្ញុំនៅក្នុងផ្ទះរបស់ខ្ញុំនេះទៀត ។

-. ដល់ខែ៧ឆ្នាំ ១៩៧៨ ក្នុងពាក់កណ្ដាលខែ៧បងស៊ិនបានមកជួបខ្ញុំហើយគាត់នាំខ្ញុំដើរឃោសនាបំផុសប្រជាជនយុទ្ធជនយុទ្ធនារីឱ្យរត់ចូលព្រៃដើម្បីតស៊ូប្រឆាំងនឹងកងទ័ពភូមិភាគកណ្ដាល ហើយប្រាប់ប្រជាជនថា នៅតទៅទៀតមិនបានទេមុខជាកងទ័ពរបស់ភូមិភាគកណ្ដាលសម្លាប់ចោលមិនខានទាំងយុទ្ធជននារីប្រជាជននិងកុមារតូចៗក៏គេមិនទុកនៅដែរដូច្នេះមានតែមួយទេគឺត្រូវតែរត់ទៅព្រៃដើម្បីរួមកំលាំងគ្នាតស៊ូសាឡើងវិញ ។
ក្រោយមកពីដើរឃោសនា ហើយបងស៊ិនបានប្រាប់ខ្ញុំថាឥឡូវនេះនៅក្នុងខែ៨ឆ្នាំ ១៩៧៨ នេះយើងត្រូវរត់ចូលព្រៃ ហើយក្នុងនេះគឺយើងត្រូវបំផុសប្រជាជនឱ្យរត់ចូលព្រៃជាមួយយើងដែរដើម្បីរួមកំលាំងជាមួយយើងរៀបចំកងទ័ពនិងបដិវត្តបន្តទៅទៀត ។
ក្រោយពីនិយាយគ្នាចប់ហើយគាត់ក៏វិលទៅភូមិគាត់វិញទៅ ។

ពេលនោះបងស៊ិនគាត់ចូលទៅក្នុងព្រៃមុនហើយ ហើយរហូតមកដល់ ខែ៨ ឆ្នាំ ១៩៧៨-បងស៊ិនបាននាំពួកព្រៃ៣៨នាក់មកយកអាវុធអា១៥បីដើមនិងអាកាមួយដើមផងមកនាំប្រជាជនទៅព្រៃអណ្ដូងព្រីង នៅក្នុងឃុំកក់ខាងកើតភូមិបែចំនួន១០០ម៉ែត្រ ។

តែក្រោយមកមានការលំបាកពេកដោយប្រជាជននិងក្មេងតូចៗខ្លះជុំរកហើយភ្លៀងទឹកយំរងាករងាខ្លាំងពេកក៏នាំគ្នាមកនៅក្នុងភូមិចាស់មួយឈ្មោះភូមិត្រាវ ឃុំកក់ ស្រុកពញាក្រែកវិញ ។

តែប្រជាជនទាំងអស់នេះក្រោយមកត្រូវកងទ័ពមកគេរទៅវិញអស់ទៅ ។គឺនៅសល់តែពួកខ្ញុំជាង៥០នាក់ទេ ។

ដល់ខែ៩ ឆ្នាំ ១៩៧៨ ពេលដែលទៅដល់ព្រៃបានប្រហែល១០ថ្ងៃបងស៊ិន និងបងស៊ីមបានហៅខ្ញុំ និងពួកព្រៃទៅចូលរួមប្រជុំនៅអណ្ដូងព្រីងចំនួន៣៤នាក់ ។

ក្នុងចំណោម៣៤នាក់ដែលបងស៊ីមទើបរៀបចំតាំងឡើងនៅក្នុងព្រៃមាន ។

១-បងស៊ីម ប្រធានទទួលរួមពួកចោរព្រៃ ។

២.បងស៊ិន ប្រធានគ ពួកចោរព្រៃ ។

៣.ស៊ាវហេង អនុគចោរព្រៃ ។

៤. សឿន ប្រធានខ ស៊ើបអង្កេតនិងសមាជិកកងតំបន់២០ បច្ចុប្បន្នសមាជិកគពួកចោរព្រៃ ។

៥.សារី ប្រធានវិបប្បធម៌ឃុំជួនតីខាងកើត បច្ចុប្បន្នទទួលខាងទាក់ទងខ្មែរនៅក្នុងរដ្ឋអំណាច ។

៦.អែ អនុឃុំកណ្ដោប្រជុំ បច្ចុប្បន្នអនុរបស់សារី ។

៧.ខន ប្រធាននិរសាស្រុកកំចាយមារ បច្ចុប្បន្នប្រធានខពួកចោរ ទំព្រៃ ៗ

៨.សន សមាជិកគយោធាស្រុកកំចាយមារ បច្ចុប្បន្នអនុខចោរ ទំព្រៃ ៗ

៩.ឡូង "ខ្ញុំ" ប្រធានក្រុមទី២ ៗ

១០.ស៊ិន អនុក្រុមខ្ញុំ ពីមុនប្រធានខយោធាស្រុកពញាក្រែក ៗ

១១.អ៊ី ប្រធានក្រុមទី១ ពីមុននៅខាងស្រុកកំចាយមារ ៗ

១២.ឈួក អនុក្រុមទី១ ពីមុនអនុខយោធាតំបន់២០ ៗ

១៣.សារី ប្រធានក្រុមទី៣ ពីមុនប្រធានក្រុមយោធាតំបន់២០ ៗ

១៤.យ៉ុនអនុក្រុមទី៣ ពីមុនយុទ្ធជនស៊ើបការតំបន់ ២០ ៗ

ពេលទៅជួបជុំគ្នា ហើយបងស៊ីមនិយាយថា ៖ យើងមកនៅទីព្រៃប៉ុណ្ណេះ ហើយគឺយើងចូលស្រុកវិញ ផែលបាន ហើយបើ យើងចូលច្បាស់ជាកងទ័ពរបស់ភូមិភាគកណ្តាលសម្លាប់ចោលទាំងអស់ ដូច្នេះមានតែយើងធ្វើការតស៊ូឡើងវិញ ហើយយើងត្រូវតែដាច់ខាតទើបយើងទទួល-បានជ័យជំនះ ហើយយើងត្រូវដំណើរការតាមរបៀបសង្គ្រាមឈ្លប ៗតែឥឡូវនេះយើងមានការទាក់ទងជាមួយយួនបានហើយ ហើយយើងមានផែនការទទឹបនិវត្តម្តងទៀតនៅក្នុងខែ១១ -១២ និងពិសេសនៅក្នុងរដូវប្រាំងខាងមុខនេះ វីរ័រួមជាមួយយួនពីខាងក្រៅ ដូច្នេះយើងត្រូវតែប្រយុទ្ធដាច់ខាតឡើង ដើម្បីរួមជាមួយគេឱ្យបានខ្លាំងឆ្លា ព្រោះលើកនេះគេមានផែនការ់ទទ័វ៉ធំណាស់ តែយើងត្រូវមានផែនការទទ្លបកងទ័ពរបស់អង្គការបណ្តើរៗដើម្បីយកអាវុធមកបំពាក់ឱ្យខ្លួនយើង ព្រោះយើងមានអាវុធមិនទាន់គ្រប់ដៃនៅឡើយទេ ហើយយើងនិងរៀបចំកសាងកងទ័ពយើងឡើងវិញបណ្តើរៗ

ហើយយើងនឹងរួមជាមួយគេដែលនឹងមកពីខាងក្រៅឱ្យបានខ្លាំងក្លា នៅរដូវប្រាំងនេះ នៅពេលដែលយួននឹងចូលមកកម្ពុជា ។

ផ្ទុយវិញ យើងប្រឆាំងតទៅទៀតឱ្យបាន ទោះការហូបអាស្រ័យរបស់យើងមានការខ្វះខាតយ៉ាងក៏ដោយក៏យើងត្រូវហូបលាយដំឡូងឬបបរ ។ ហើយបើយើងទៅពឹងពាក់ខ្មែរយើងនៅខាងក្នុងក៏ខ្មែរយើងគេមិនទទួលយើងទេ ព្រោះយើងជាមនុស្សដែលគេមិនហ៊ានទទួលយើងទេ ដូច្នេះយើងត្រូវនៅក្នុងព្រៃ ហើយយើងត្រូវតែតស៊ូជាដាច់ខាត និងត្រូវតែល័ក្ខារឱ្យបានជាដាច់ខាត ។ ចំពោះអាវុធវិញ យើងមានការខ្វះខាត គឺយើងនៅមានតិចនៅឡើយ គឺមានអាវុធអាកា៤ដើម និងអឹម១៥ -៦ដើម និង បេ៤០មួយដើម - គ្រាប់មានពីគ្រាប់ អក់ក្លូនមួយគ្រាប់ និងមានក្លូនមួយគ្រាប់ និងអាវុធខ្លី២៥មួយដើម ដូច្នេះយើងត្រូវតែធ្វើសង្គ្រាមឈ្លប ដូចកាលពីដើម គឺជំនាន់ខ្ញុំ យើងធ្វើតាំងពីបាតដៃទទេ រហូតយើងទទួលជ័យជំនះបានមករហូតដល់បច្ចុប្បន្ន តែមកពីនេះដល់ផ្ទុយវិញ គឺ

ងក៏ទៀត

យើងមានអាវុធប៉ុណ្ណឹងដែរ តើមិនល្អះអី ។ ឯអាវុធយើងគឺនៅអាមេរិកា កណ្ដាលបើចង់បានអាវុធនោះ ទាល់តែយើងទៅដណ្ដើមយកមកវិញ ។

បញ្ហានេះខ្ញុំចង់និយាយថា យើងត្រូវទៅកំទេចកំលាំងរស់របស់ពួកវា ជាតូចៗ ដើម្បីរឹបយកអាវុធមកបំពាក់ឱ្យខ្លួនយើង ដើម្បីធ្វើការតស៊ូបន្តទៀត ។ ឯចំពោះខ្មែរយើងដែលនៅក្នុងរដ្ឋអំណាចគឺយើងមានគោរី និងមិត្តអែ ជាអ្នកទាក់ទងរៀបចំកំលាំងទៀងទិញ គឺ កំលាំងកងឈ្លបឃុំ និងនៅតាមមុខក្រូញ និងនៅក្នុងសហករ និងក្នុងឃុំទៀងទិញឱ្យបានឆាប់រហ័ស ។ ហើយឱ្យខ្មែរយើងនៅខាងក្នុងទាំងអស់នេះត្រៀមលាក់ស្រូវ និងយកអង្ករលាក់ និងលាក់អំបិលទុកជួយកងទ័ពយើងនឹងបដិវត្តនៅរដូវប្រាំងឆ្នាំ៧៨ ។

ខែ០៩ ឆ្នាំ ១៩៧៨ ក្រោយពីបងស៊ឹមហៅទៅប្រជុំហើយ ហើយគាត់បានលើផែន

ការសហការណ៍ជាមួយយួនត្រួសៗមិនច្បាស់ ពេលនោះខ្ញុំបានចោទសួរបងស៊ឹមថា៖

បង - បងស៊ឹមថា យើងទៅទាក់ទងយួនបាន តើបានមែនទេបង ។

-. ជាមួយនេះបងស៊ឹន បាននិយាយប្រាប់ខ្ញុំថា៖

ដំបូងនៅដើមខែ០៨ ឆ្នាំ ១៩៧៨ នេះបងស៊ឹមបានឱ្យនិរសារគាត់ទៅទាក់ទងយួននៅ-ខាងកើតភូមិត្នោតចូលទៅដីក្រោមស្រុកយួន ដើម្បីឱ្យដឹងគ្នាឱ្យហើយស្រួលក្នុងពេលដែលបងស៊ឹម ទៅទាក់ទងពិភាក្សាអំពីផែនការរបស់ខ្មែរយើងនៅខាងក្នុងមួយចំនួន ។

ពេលដែលទៅនោះគឺបងស៊ឹមគាត់ឱ្យនិរសារគាត់ទៅ៤នាក់ មានឈ្មោះ យាតមួយ និងសារ៉ាតមួយ និង អ៊ុំមួយ និង ចនមួយ ក្នុងនេះមានឈ្មោះ យាត ចេះភាសាវយួនផង ។

ក្រោយពីនិរសារគាត់ទាក់ទងយួនបានសម្រេចតាមផែនការហើយត្រឡប់មកវិញ ។

ក្រោយពីមកវិញហើយបងស៊ឹម គាត់បានទៅទាក់ទងយួនខ្លួនគាត់ ដោយឱ្យនិរសារគាត់ទាំង៤នាក់នោះទៅជាមួយ ។

ចំពោះបងស៊ឹមគាត់ទៅទាក់ទងយួនពេលនោះគឺគាត់បានស្នើឱ្យយួនជួយពួកយើងដែលរត់មកនៅក្នុងព្រៃ ដែលមានគ្នាជាងមួយរយនាក់ គឺខាងយើងជាង៣០ នាក់ និងខាង-បងស៊ឹម មានជាង២០ នាក់ និងខាងតាសារី ដែលជាចាស់ទុំជាង២០នាក់ដែរ ។

ហើយនៅក្នុងនេះមាននារី២០ នាក់ផង ហើយ និងប្រជាជនចំនួនមួយពាន់ គ្រួសារ ហើយបងស៊ឹមស្នើពឹងឱ្យគេជួយរើបើផ្លូវដើម្បីឱ្យខ្មែរដើ និងប្រជាជនរត់ទៅស្រុកយួនផង ដើម្បីសុំជ្រកនៅក្នុងដីយួនផង ។

-. ពេលនោះគឺតាត់ទាក់ទងយួនឈ្មោះធីងប្រធានកងពល ដែលមិនដឹងលេខកងពលទេ ហើយយួនគេថា: មិនអីទេគេនឹងជួយយើង ដែលចាំដល់ខែ១១ ឬ ១២ និងរដូវប្រាំងនេះ ទីវ៉ៃកម្ពុជាម្តងទៀត ហើយគេថាគេជួយយើង និងសហការជាមួយខ្មែរយើងនៅខាងក្នុង ។ ហើយគេថាជាទិសរបស់គេលើកនេះគឺគេមានផែនការបុកបីមុខសញ្ញា ។ គឺមុខសញ្ញាទីមួយគឺគេបុកខាងស្វាយរៀងដោយប្រើកំលាំងទ័ពគេបីកងពល ។មុខសញ្ញាទីពីគឺនៅច្រកភូមិត្នោត និងផ្សារក្រដាល ដោយប្រើកំលាំងទ័ពគេពីកងពល ។ និងមុខសញ្ញាទីបីនៅខាងច្រកមេមុត ដោយប្រើកំលាំងកងទ័ពគេ៤កងពល ។ ហើយគេឱ្យកំលាំងយើងនៅខាងក្នុង នៅពេលដែលគេវ៉ៃចូលមកនេះគឺគេឱ្យយើង-នៅទទួលភារៈកិច្ចខាងក្នុង គឺបញ្ហាទីមួយ គេឱ្យយើងត្រៀមកំលាំងយើង ដែលមានទាំងអស់ត្រៀមទីវ៉ៃឈ្លបកងទ័ពរបស់អង្គការពីខាងក្រោយ ដើម្បីធ្វើឱ្យច្របូកច្របល់ នៅពេលដែលប្រយុទ្ធជាមួយកងទ័ពយួននៅពីខាងក្រៅ ដើម្បីដណ្តើមជ័យជំនះលើ កងទ័ពរបស់បដិវត្តកម្ពុជា ។ ក្រៅពីនេះគឺយួនគេឱ្យកំលាំងប្រជាជនដែលនៅក្នុងព្រៃទាំងអស់នោះត្រៀមប្រមូលផលស្រូវឱ្យបានច្រើន ហើយធ្វើកន្លែងដាក់ឱ្យបានស្រួលនៅពេលដែលកងទ័ពយួនគេវ៉ៃចូលមកក្នុងដីកម្ពុជាយើង ។នៅចុងឆ្នាំ-១៩៧៨ និងដើមឆ្នាំ ១៩៧៩ ខាងមុខនេះ ។

-. ដល់លើកទីបីដែលបងស៊ីមតាត់បានទៅទាក់ទងយួនម្តងទៀតបន្ទាប់ពីនេះដែលៈ នៅក្នុងខែ ៨នេះដ ដែល តែពេលនោះមិនបានសម្រេចទេដោយកងទ័ពរបស់អង្គការដាក់មីន និងចាំរ៉ូងច្រើន និងការពារនៅមុខសញ្ញានេះផង ហើយនិងផ្ទុះមីនត្រូវ-ស្លាប់និរសាតាត់ពីនាក់ទៀតផង គឺមិត្ត ណាត និងមិត្ត សារ៉ាត ហើយយើងក៏ដាច់ការ

ទាក់ទងជាមួយពួនចាប់តាំងពីពេលនោះមក ។
ក្រោយពីប្រជុំហើយមកបងស៊ុម និងបងស៊ុន បាននៀបចំចាត់តាំងកំលាំងជាបីមុកព្រួញ ។គឺមុកព្រួញទីមួយមានគ្នា១០ នាក់ មានអាវុធបីដើម និងកាំភ្លើងខ្លីមួយដើម និងគ្រាប់បែកដៃពីគ្រាប់ ។ ហើយក្នុងមុកសញ្ញាទីមួយនេះគឺមានមិត្តអ៊ីប្រធាន និងមិត្ត យ៉ូក អនុប្រធាន ឯផែនការគឺបងស៊ុម គាត់ណែនាំឱ្យទៀតរៀមដើរល្បាតកងទ័ពរបស់អង្គការ នៅពេលដែលដើរដាច់ពីចំណោមគ្នា ហើយ ដើម្បីយកអាវុធ មកបំពាក់ឱ្យខ្លួន ។
មុកព្រួញទីពី គឺមាន រួបខ្ញុំជាប្រធាន និង មិត្តស៊ិនអនុប្រធាន ហើយនិងមានយុទ្ធជន ៨ នាក់ផង ដោយឱ្យពួកខ្ញុំទាំង៨នាក់នេះទៅត្រៀមដើរល្បាតកងទ័ពរបស់អង្គការនៅមុកសញ្ញាភូមិឆ្លក ក្នុងឃុំកក់ ស្រុកពញាក្រែក ។
មុកព្រួញទីបី មានមិត្តសារីប្រធាន និងមិត្ត យ៉ុន អនុប្រធាន ហើយនិងមាន :

យុទ្ធជនចំនួន៨នាក់ដែរ ឱ្យទៅត្រៀមធ្វើល្បបនៅភូមិសទ្ធិ ឃុំកក់ ក្រោយពីបងស៊ីម និងបង ស៊ុន គាត់ចែកមុខព្រួញ ហើយពួកខ្ញុំក៏វិលទៅកាន់មុខព្រួញរៀងៗខ្លួន ។ បន្ទាប់មកខ្ញុំបាននាំពួកខ្ញុំមួយក្រុមមកធ្វើជុំរុំនៅ ត្រៀមចាំ ធ្វើល្បបនៅក្នុងកន្លែងដែលយុ ត្រៀមនោះគឺនៅចម្ងាយពីភូមិធ្លកឈៀងខាងត្បូងប្រហែល៥០០ម៉ែត្រ ។ ហើយខ្ញុំបានចាត់តាំងកំលាំងឱ្យទៅតាមដានកងទ័ពអង្គការនៅខាងមុខកន្លែងត្រៀម គឺនៅក្នុងភូមិរាល់ថ្ងៃ ។

ដល់ក្រោយមកបានប្រហែល១០ ថ្ងៃខ្ញុំបានចាត់តាំងឈ្មោះ អយ និងឈ្មោះ សារិន ទៅឃ្លាំចាំមើលកងទ័ពរបស់អង្គការទៀតដើម្បីវ៉ៃឆ្មក់ ។ តែពេលដែលពួកខ្ញុំទាំងពីនាក់នេះទៅគឺបាន ទៅលួចកាប់ស្លឹងស៊ីមិនដឹងខ្លួនស្រាប់តែកងទ័ពរបស់អង្គការបាញ់របួសទាំងពីនាក់ ហើយពួកនេះបាញ់តវិញ ហើយគិចរួចមកវិញ ។

ក្រោយមកខ្ញុំបានដកពួកខ្ញុំមកត្រៀមនៅខាងកើតភូមិធ្លកប្រហែល ៦០០ម៉ែត្រ ។ ពេលដែលមកនៅទីនេះបាន៨ថ្ងៃទៀត ក៏កងទ័ពអង្គការតាមទៅបាញ់ពួកខ្ញុំទៀត - ពេលនោះពួកខ្ញុំក៏រត់មកនៅខាងជើងព្រែកមួយចម្ងាយពីភូមិធ្លកប្រហែល៥០០ម៉ែត្រនិង ហើយពីភូមិទៅកន្លែងដែលខ្ញុំនៅនោះគឺប្រហែលមួយគីឡូម៉ែត្រ ។

ជាមួយនេះខ្ញុំបានមកជួបបងស៊ុននៅកន្លែងនោះដែរ គឺគាត់មាននារី១២នាក់ និង - និរសា ៤នាក់ទៀត ។ ជាមួយនេះបងស៊ុនគាត់បានសួរខ្ញុំថា : ម៉េចទៅសភាពការណ៍នៅភូមិធ្លកបានជាមិត្តឯងរត់ទីណាត់ទីណែងមកដែរ .

-.ជាមួយនេះខ្ញុំបានរាយការណ៍ឱ្យគាត់ថា : ចំពោះសភាពការណ៍នៅក្នុងភូមិធ្លកគឺមានកងទ័ពរបស់អង្គការមកបាញ់ពួកខ្ញុំពីរដង ហើយ និងធ្វើឱ្យរបួសពួកយើងអស់ពីនាក់ទៀត គឺឈ្មោះ មិត្តអយ និងឈ្មោះ សារិនចំពោះមិត្តអយខ្ញុំយកមកមិនបានទេ គឺយកបានតែមិត្តសារិន

ទេ ។

--.ជាមួយនេះបងស៊ុននិយាយថា : ខ្ញុំថាគិតឱ្យនិរសាទៅ ទៅមិត្តឆ្ងង ឯងដែរ តែបើមកហើយក៏ស្រួលដែរ ។

--. ជាមួយនេះខ្ញុំបានសួរគាត់វិញថា : ចុះរបួសបងគិតយ៉ាងម៉េច ។

គាត់និយាយថា ចាំមើលយើងឆ្លងទៅខាងលិចព្រែករកកន្លែងនៅបានស្រួលសិនចាំយើងទៅយកមក ។

--. ខ្ញុំបានប្រាប់គាត់ថា : ចំពោះអ្នករបួសនោះគឺត្រូវអត់បាយ៦ថ្ងៃហើយ បងជួយផង ។

--.ជាមួយនេះបងស៊ុនបានឱ្យខ្ញុំ និង មិត្តស៊ុន យកបាយរបស់គាត់ដែលលាយដំឡូងមួយកូនឆ្នាំង ទៅឱ្យមិត្តដែលរបួសនៅក្នុងព្រៃនោះហូប ។

ពេលនិយាយចប់ហើយខ្ញុំ និងស៊ុន បានយកបាយមកឱ្យមិត្តអយ ដែលរបួសដើមិនរួច ។

ជាមួយនេះមិត្តអយសួរខ្ញុំថា : បងមានពេទ្យមកដែរ ។

ខ្ញុំប្រាប់គាត់វិញថា ពេទ្យអត់មកទេ ខ្ញុំមកនេះគឺគ្រាន់តែយកបាយមកឱ្យមិត្តអយឯងទេ ព្រោះសភាពការមានការលំបាកខ្លាំងដែរ តែចាំមើលខ្ញុំរកកន្លែងនៅបានស្រួលចាំខ្ញុំមកយកមិត្តឯងទៅ ហើយឥឡូវនេះខ្ញុំទៅវិញហើយព្រោះខ្ញុំមកនេះគឺដើរផងលួនផងទុំទំមកដល់ ។ កន្លែងដែលមិត្តអយនៅនេះគឺចម្ងាយពីភូមិធ្លក៦០០ម៉ែត្រមកត្បូង ។

ពេលដែលខ្ញុំមកដល់វិញបងស៊ុនបានសួរខ្ញុំថា ម៉េចទៅអ្នករបួស ។

--. ខ្ញុំប្រាប់គាត់វិញថា ចំពោះមិត្តអយ គឺមុខឡើងផ្លាំងអស់ហើយ ឯរបួសគាត់ឡើងស្អុយ ។ បងស៊ុននិយាយថា បើអីចឹងយើងសម្រាកសិនទៅ ចាំស្អែកយើងទៅយកមក ។

--.ដល់ស្អែកទៀតម៉ោងប្រហែល៩ ព្រឹកកងទ័ពរបស់អង្គការបានទៅតែបាញ់ពួកខ្ញុំងាប់អស់ពីនាក់ និងរបួសនារីម្នាក់ទៀត ។

ពេលនោះពួកខ្ញុំរត់បែកគ្នាខ្លះរត់ទៅខាងជើង ចំពោះរូបខ្ញុំរត់មកខាងត្បូង ហើយ
ជាប់បានតែគ្នាបីនាក់ទេ គឺមិត្ត លន និងមិត្ត ស៊ិន និងមិត្តខន ហើយខ្ញុំក៏មកនៅក្នុងព្រៃ
បាក់អាយចម្ងាយពីកន្លែងដែលបាញ់នោះប្រហែលមួយគីឡូ កាលនៅទីនោះបាន៥ថ្ងៃ ខ្ញុំ
ទាំងនៃនាក់ក៏រត់មកនៅព្រៃអណ្ដូងព្រីងវិញ ពេលនោះខ្ញុំបានជួបជាមួយបងស៊ិន និង
មិត្តគី មុកព្រួញទីមួយ និងមិត្ត សា ទីប្រធានមុកព្រួញទីបី និងជួបជុំគ្នាវិញទាំងអស់ ។
ដែលមានចំនួនជាង៥០នាក់ ។

ជាមួយនេះបងស៊ិនបានសួរខ្ញុំថា មិត្តឡូង ឯងរត់ទៅតាមណាក៏បាត់ឈូរម្ល៉េះ ម៉េចក៏មិន-
រត់មកតាមខ្ញុំ ។

-. ខ្ញុំប្រាប់គាត់វិញថា: រត់ទៅយ៉ាងម៉េចបើគ្រាប់បាញ់ដូចគេបាចអង្ករមកអីចឹង ហើយ
នៅចំពីមុខខ្ញុំមានកាំភ្លើងម៉ាស៊ីនមួយផង ។

-. ជាមួយនេះគាត់បានប្រាប់ខ្ញុំថា: ចំពោះខាងគាត់កងទ័ពអង្គការយកបានកាំភ្លើងពី-
ដើមហើយ គឺអាកាមួយដើម និងកាំភ្លើងបេ ៤០ មួយដើមទាំងគ្រាប់ផង ។
និងអង្គរស់ពីទីទ និងថ្នាំងពី និងអង្រឹងពីផង ។

ក្រោយមកពួកខ្ញុំស្រោមកនៅក្នុងព្រៃអណ្ដូងព្រីងនេះបានបីថ្ងៃក៏បងស៊ីមបានមកជួបជាមួយពួក
ខ្ញុំនៅក្នុងព្រៃអណ្ដូងព្រីងនេះដែរ ។ ក្នុងនេះមិរសា គាត់មកជាមួយគាត់នៃនាក់ផង ។
ជាមួយនេះបងស៊ីម និយាយទៅរកបងស៊ិនថា ៖ស៊ិនឯងមានអង្គប៉ុន្មានដែរ
បងស៊ិននិយាយថា អង្គនៅសល់ទាំងអស់តែ ២០ ទីទេ

-. បងស៊ីមនិយាយទៀតថា ឥឡូវនេះយើងដោះស្រាយអង្គមិនបានទេ ដូច្នេះយើង
ត្រូវដើរកដីកដំឡូងទុកលាយបានពុ មឿងទៀតទាល់តែយើងចាត់តាំងកំលាំងឱ្យទៅ
ទាក់ទងខ្មែរយើងនៅខាងក្នុងវត្តអំណាចដែលជាខ្មែរបាសរបស់យើង ទើបយើងដោះ -

ស្រាយបានខ្លះ ។ ក្រោយពីប្រាប់បងស៊ុន ហើយបងស៊ុនក៏គាត់ត្រឡប់ទៅអណ្តូងស្វាយវិញ ដែលនៅចម្ងាយពីទីព្រអណ្តូងព្រីង ប្រហែល ២ គីឡូម៉ែត្រ ។

-. បន្ទាប់មកបងស៊ុន បានហៅខ្ញុំ និង ស៊ុន និងសន និង ឡន ទៅប្រជុំណែនាំថា : ឥឡូវនេះមិត្តឯងត្រូវទទួលភារកិច្ចទៅទាក់ទងខ្មែរយើងនិងពង្រឹងខ្មែរយើងនៅខាងក្នុងរដ្ឋអំណាចឡើងវិញ ហើយឱ្យពាំកំលាំងស្នូលរបស់យើង រៀបចំកសាងកំលាំងថែមទៀត ដើម្បីបង្កប់នៅក្នុងមូលដ្ឋានម្តងទៀត ហើយឱ្យត្រៀមជាអង្គនៅតាមខ្មែរនិមួយៗនិងអំបិល ដើម្បីឱ្យកងទ័ពយើងនៅពេលដែលវើបដិវត្តនៅក្នុងរដូវប្រាំងខាងមុខនេះ ។

-. ក្រោយពីបងស៊ុនគាត់បានណែនាំខ្ញុំហើយ ពួកខ្ញុំទាំងបីនាក់ បានទៅទាក់ទងខ្មែររបស់ខ្ញុំឈ្មោះ ឯន ប្រធានមុកព្រួញប្រចាំ ភូមិទីព្រអង្គរក្នុង នៅពេលប្រហែលម៉ោង ៥ ល្ងាច ។

ពេលទៅជួបភ្លាមបង ឯននិយាយថា ពីមិត្តឯងនៅឯណាហ្នឹង យើងខានជួបគ្នាយូរហើយ ឥឡូវមិត្តឯងនៅខាងកងទ័ពរបស់អង្គការអី ។

-. ខ្ញុំប្រាប់គាត់ថា : ខ្ញុំនៅជិតពុលឹងទេ តែខ្ញុំនៅក្នុងទីព្រហើយ ។ ចុះសភាពការណ៍នៅក្នុងភូមិយើងយ៉ាងម៉េចហើយ មានកងទ័ពដើរចេញចូល ឬក៏មានដើរញឹកញាប់ទេ ។

-. គាត់និយាយថា : ឥឡូវនេះឃើញយួន ដើរម្តង មិនសូវជាញឹកញាប់ទេ ។ ហើយការដែលរស់នៅក្នុងភូមិក៏មិនទាន់ឃើញមានអីទេ ។

-. ខ្ញុំនិយាយថា បើអីចឹងខ្ញុំសុំទៅផងបានទេ ។

-. គាត់និយាយថា មិនបានទេព្រោះយើងជាមនុស្សផ្លែកពីគេ . ហើយប្រជាជនក៏កាន់

ដែលយល់ពីមាគ៌ាបដិវត្តជាបណ្តើរៗ ហើយ ហើយការឃោសនា គឺយើងធ្វើឡើងពីលើកមុន ទៀតដែលបានហើយ តែបើមិត្តឯងមកទាក់ទងខ្ញុំ គឺមិត្តឯងមកទាក់ទងខាងក្រៅបានហើយ

-. ជាមួយនេះខ្ញុំក៏សួរគាត់វិញថា បើអ៊ីចឹងបងអាចទទួលភារៈកិច្ចជួយចំនួនសម្រាប់អនុវត្តន៍នៅក្នុងភូមិតើបងធ្វើបានទេ ។

-. គាត់និយាយថា បើការងារនោះគាត់ធ្វើបានគឺគាត់នឹងខំធ្វើតទៅទៀត ។

-ខ្ញុំនិយាយទៀតថា : បើអ៊ីចឹងខ្ញុំសុំស្នើឱ្យបងឯងពង្រឹងខ្សែយើងឡើងវិញ ហើយនិងកសាងកំលាំងរបស់យើងថែមទៀត ។ តែត្រូវល័ក្ខាកុំឱ្យបែកការ ត្រូវពិនិត្យឱ្យបានម៉ត់ ក្រៅពីនេះខ្ញុំស្នើឱ្យបងជួយអង្ករ និងអំបិលមួយចំនួនផងបានទេ ។ ដើម្បីយកទៅឱ្យកងទ័ពយើងដែលនៅក្នុងព្រៃឯណោះ ។

-. គាត់សួរខ្ញុំថា កងទ័ពយើងនៅឯណា ច្រើនឬតិច ។

-ជាមួយនេះខ្ញុំនិយាយភូតគាត់ដើម្បីឱ្យគាត់មានជំនឿលើខ្សែរបស់ខ្ញុំថា : កងទ័ពយើងនៅឆ្ងាយពីនេះ ហើយកងទ័ពយើងមានច្រើនណាស់ គឺរាប់កងពល នៅពេញតែ-ព្រៃ តែផ្ទៀងមានការខ្វះខាតជាចាំបាច់មួយពេលពីពេលហើយ ហើយកងនៅក្នុងព្រៃក៏ពិបាកដែរ ។ ហើយបើបងអាចលួចជាស្រូវ ហើយយកទៅធ្វើជាអង្ករក៏យើងខអាចមានលទ្ធភាពដែរព្រោះបងនៅខាងក្នុងរដ្ឋអំណាច ។

ឬមួយធ្វើតាមវិធីណា ក៏បានតាមការជាក់ស្តែងរបស់បងនៅខាងក្នុងព្រោះឧបភាពការណ៍នៅខាងក្នុង បើតាមបងនិយាយក៏មានការលំបាកដែរ ។

-. ជាមួយនេះគាត់និយាយថា : ឃើញភាពការណ៍ផ្ទៀងនេះកាន់តែតឹងតែងជាងមុន ។ ហើយព្រោះពីឃុំគេបើកមកគឺត្រឹមតែប្រជាជនរូបមួយពេលៗទាល់ពេលមិនដែលឃើញ-

នៅយល់ទេ តែចាំមើលខ្ញុំទៅទាក់ទងខ្មែរយើងនៅក្នុងភូមិមើលក្រែងជួយដោះ-ស្រាយបានខ្លះ ។

-.ជាមួយនេះខ្ញុំសួរគាត់ថាចុះបង ផានគាត់នៅឯណាសព្វថ្ងៃ ។

គាត់ថា ផានសព្វថ្ងៃទទួលជាសមាជិកទីឃុំដូនតីខាងលិច តាំងពីក្រោយផ្ទុះអាវុធមក-

-.ជាមួយនេះខ្ញុំបានប្រាប់គាត់ថា បងផាន ជាខ្មែរយើងដែរ ហើយបើឯងទាក់ទងក៏បានដែរមិនអីទេ ។ ហើយថ្ងៃស្អែកនេះខ្ញុំមកជួបបងឯងនៅទីនេះទៀត ហើយខ្ញុំសុំបាយបង ហូបមួយពេលផង [illegible] ។

ក្រោយពីនិយាយចប់ ហើយខ្ញុំបាននាំពួកខ្ញុំទាំងបីនាក់ទៅលាក់ខ្លួននៅខាងក្នុងភូមិព្រៃអង្គ ក្នុងចម្ងាយមួយគីឡូម៉ែត្រ ។

ដល់ថ្ងៃស្អែកខ្ញុំបាននាំគ្នាទាំង៤នាក់ទៅជួបគាត់នៅកន្លែងដដែលទៀត ។ ពេលទៅជួប ហើយគាត់បានឱ្យបាយមកពួកខ្ញុំទាំង៤នាក់ល្មមហូបពីពេលព្រឹកល្ងាច ហើយគាត់និយាយប្រាប់ខ្ញុំថា: សភាពការប្រជាជនមានការតឹងតែងដែរ លួកមុតពុ តែមិនអីទេ ដំបូងវាអីចឹងហើយ ចាំមើលយើងធ្វើយូពុទៅគឺកាន់តែយល់ និងស្រួលវិញមិនខាន ។ តែបញ្ហានេះខ្ញុំនិងខំប្រឹងប្រែងតទៅទៀត ។

ខ្ញុំនិយាយថា: បញ្ហានេះទាល់តែយើងខំទាំងអស់គ្នា ដើម្បីសម្រេចផែនការរួមរបស់ខ្មែរយើងទាំងអស់គ្នា ទើបយើងធ្វើបានខ្លាំង ។

-. ជាមួយនេះគាត់និយាយថា ខ្ញុំមិនហ៊ាននៅយូរទេខ្លាចគេសង្ស័យយើង ។

ក្រោយពីនិយាយគ្នា ហើយខ្ញុំក៏វិលមកសម្រាកនៅក្នុងកន្លែងដែលខ្ញុំនៅពីមុន ។

៧.បន្ទាប់មកខ្ញុំបានឆ្លងមកភូមិពរោង ឃុំដូនតីខាងលិច ខ្ញុំបានមកជួបជាមួយបងអាំ នៅពេលដែលគាត់កំពង់តែបបក់ត្រីនៅកន្លែងពើកខាងកើតភូមិពរោង ជាមួយនេះខ្ញុំបានសួរគាត់ថា បងនៅក្នុងភូមិមាកងទ័ពនៅទេ ។ ជាមួយនេះបងអាំដែលជាខ្មែរ-ចាស់របស់ខ្ញុំនិយាយថា: កងទ័ពអត់មែននៅទេ តែមានដើរចល័តតាមភូមិក្នុងម្ដងប្រាំមួយប្រាំពីនាក់ ។

-. ខ្ញុំសួរគាត់ទៀតថា: ចុះការហូបអាស្រ័យឥឡូវយ៉ាងម៉េចដែរ ហើយអង្ករធ្វើខ្លួនឯងឬក៏បើកពីឃុំមក ។

-. បងអាំនិយាយថា ចំពោះអង្ករឥឡូវនេះបើកពីឃុំមកតាមកំណត់ប្រជាជន ។

-ខ្ញុំសួរគាត់ទៀតថា: ចុះបងបងសយ គាត់នៅផ្ទះទេ ។

-. បងអាំនិយាយថា គាត់នៅទេ ។ ខ្ញុំប្រាប់គាត់ថា បើអីញ្ចឹងបងអាំឯងទៅ-ហៅគាត់មកជួបខ្ញុំឥឡូវនេះបានទេ ។ គាត់ថា: បានហើយគាត់ក៏ទៅហៅបងសយមកជួបជាមួយខ្ញុំ ហើយជាមួយនេះខ្ញុំនិយាយលេងជាមួយបងសយថា បងសយឥឡូវធាត់ណាស់ បងសយ និយាយថាចុះមានអី ។

៨. ជាមួយនេះខ្ញុំនិយាយថា : ខ្ញុំមកនេះគឺខ្ញុំសុំទាក់ទងបងសយឯងដើម្បីស្នើបងជួយរកអង្ករ និងអំបិលមួយចំនួន ដើម្បីយកទៅឧបត្ថម្ភឱ្យកងទ័ពយើងដែលនៅក្នុង ព្រៃហើយកំពង់តែមានការខ្វះខាតយ៉ាងខ្លាំង ដូច្នេះស្នើបងជួយដោះស្រាយផង ។

ជាមួយនេះបងសយ និយាយថា ចំពោះអង្ករ និងអំបិល នេះមានការលំបាកដែរព្រោះពីឃុំមក គេស្ទើរតែបើកតាមកំណត់ប្រជាជនត្រឹមត្រូវតែម្ដង តើមិត្តឯងយកឥឡូវ ?

-. ខ្ញុំនិយាយថា បើបងឯងឱ្យខ្ញុំឥឡូវក៏បានដែរ ។

បងសុយថា ផ្លូវនេះមិនទាន់បានទេ ចាំ មើលពីបីថ្ងៃទៀត បើក្រែងខ្ញុំកិបកង-ពីប្រជាជនបានខ្លះយកមកឲ្យមិត្តឡុងឯង ។

-. មុននិងបែកគ្នា ទៅខ្ញុំបានប្រាប់បងសុយថា : បងសុយពេលដែលបងឯងទៅវិញខ្ញុំស្នើឲ្យបងទៅប្រាប់បង ផាន ផងថាឲ្យគាត់មកជួបខ្ញុំនៅកន្លែងដើមពោធិខាងកើតវត្តព្រៃអង្គក្រៅ នៅវេលាម៉ោង៦ល្ងាចនេះកុំខាន ហើយបងសុយ និង បងអាំក៏ទៅកន្លែងគាត់វិញទៅ ឯខ្ញុំនិងពួកខ្ញុំបានមកកន្លែងសំរាកវិញ ។

-. ដល់ម៉ោង៦ខ្ញុំ និងលន បានទៅចាំបងផាននៅកន្លែងដែលបានកំណត់នោះ ។ ហើយខ្ញុំនិងលន បាននៅចាំទីនោះមួយសន្ទុះទើបឃើញបងផាន ដើរមកជួបខ្ញុំ និងមិត្ត-លន ហើយគាត់សួរខ្ញុំថា : ផ្លូវមិត្ត ឡុង ឯងនៅឯណាសព្វថ្ងៃ ។

-ជាមួយនេះខ្ញុំបានឆ្លើយប្រាប់គាត់ថា : ខ្ញុំនៅឆ្ងាយណាស់ គឺនៅឯព្រៃណុះ ។ ជាមួយនេះបងផានសួរខ្ញុំទៀតថា : ម៉េចទៅ នៅព្រៃមានសភាពការយ៉ាងម៉េចដែរ ខ្ញុំឮថាកងទ័ពរបស់អង្គការនុករកទាល់តែថ្ងៃ គ្នាល្បានតែខគេចាប់ពួកឯងបានអស់ហើយ

-. ជាមួយនេះខ្ញុំប្រាប់គាត់ថា គេចាប់អស់មួយចំនួនដែរ នៅពេលដែលចូលទៅ-ព្រៃនោះ ហើយផ្លូវនេះកងទ័ពយើងកំពង់តែមានការខ្វះខាតយ៉ាងខ្លាំង ដូច្នេះខ្ញុំមកទាក់ទងជាមួយបងនេះគឺដើម្បីឲ្យបងជួយ ជាអំបិល និងអង្ករមួយចំនួន ដើម្បីឧបត្ថម-កងទ័ពរបស់យើង ។ ព្រោះអត់បាយពីបីថ្ងៃហើយ ។

-ជាមួយនេះបងផាននិយាយថា : ចាំមើលខ្ញុំទៅទាក់ទងខ្មែរយើងនៅក្នុងមូលដ្ឋាន-មើលក្រែងបានខ្លះយកមកឲ្យមិត្ត ឡុង ឯង ។

ហើយចាំមើលប្អូនដប់ថ្ងៃទៀតបើបានខ្ញុំយកមកឲ្យមិត្តឡុងឯង នៅកន្លែងនេះ ។

ក្រោយពីនិយាយគ្នាចប់ហើយគាត់ក៏វិលទៅកន្លែងគាត់វិញទៅ ។ខ្ញុំក៏មកវិញដែរ ។

.. ដល់ពេលព្រឹកឡើងមិត្តខន និយាយប្រាប់ខ្ញុំថា: ឡុងឯងទៅរាយការណ៍ឱ្យបងស៊ុម ទៅថា: យើងបានទាក់ទងកំលាំងយើងដែលជាកំលាំងឈ្លបនៅខាងក្នុងបានអង្គខ្លះហើយ នៅតែកំណត់ថ្ងៃទៅយកទេ ឯចំពោះខ្ញុំ និងសនទៅធ្វើការនៅភូមិពានទ្រៃជ ហើយ និងភូមិសុវណ្ណគុម និងភូមិបុសខ្លាន ទៀត ។ ហើយមិត្ត ខន និយាយទៀតថា: មិត្តឡុង ឯងទៅតែបីថ្ងៃបានហើយ ។

ក្រោយពីនិយាយគ្នារួចហើយខ្ញុំក៏មកកាត់តាមផ្លូវចាក់សំរោងទៅតាមទ្រពាក់អាយ តែ ពេលនោះខ្ញុំទើបតែទៅដល់ចុងភូមិសុវណ្ណគុមខាងត្បូងក៏កងទ័ពពិតចាប់ខ្ញុំបាននៅពេល នោះតែម្ដង គឺចាប់នៅក្នុងថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៧៨ ។ល។

ធ្វើនៅថ្ងៃទី១១ វិច្ឆិកា ១៩៧៨

ហត្ថលេខា :

ឈិន.ឡុង

មិត្តអ្នកសួរ

ពូល.ផាលី

អំពីបញ្ជីឈ្មោះមនុស្សទាក់ទងក្នុង

ប្រវត្តិ យិន ឡុង

-----------

១- សំបូ មុនចាប់លេខាស្រុកកំចាយមា ។

២- ស៊ុម បច្ចុប្បន្នរត់ចូលទៅនៅទីព្រៃអណ្តូងព្រីងខាងកើតភូមិតាថៃ ឃុំកក់ ស្រុកពញាក្រែក។

៣- ឡាង សមាជិកឃុំដូនតី បច្ចុប្បន្ន ចាប់ ។

៤- ជៀប ប្រធានសហករភូមិតាមរាក់ បច្ចុប្បន្ន ចាប់ ។

៥- សេង ប្រធានភូមិតាមស្វាយ បច្ចុប្បន្ន ចាប់ហើយ ។

៦- ហឿង សមបជិកឃុំឧត្តមានជ័យ បច្ចុប្បន្ន ចាប់ហើយ ។

៧- ប៉ែង ប្រធានភូមិថែមក្អម ឃុំឧត្តមានជ័យ បច្ចុប្បន្ន ចាប់មិនបាន ។

៨- ភុន អនុប្រធានឃោសនាស្រុកពញាក្រែក បច្ចុប្បន្ន ចាប់ហើយ ។

៩- សាលី ជំនួយការស្រុកពញាក្រែក បច្ចុប្បន្ន ចាប់ហើយ ។

២០- ផល់ ប្រធានរោងពុម្ពស្រុកពញាក្រែក បច្ចុប្បន្ន ចាប់ហើយ ។

២១- សារ៉ន ប្រធានឃោសនាស្រុកពញាក្រែក បច្ចុប្បន្នចាប់ហើយ ។

២២- បូ ប្រធានគទពីស្រុកពញាក្រែក បច្ចុប្បន្ន ចាប់ហើយ ។

២៣- ឡាត់ ប្រធានគ ក្រោយពេលដែលផ្ទុះអាវុធខ្ញុំចាប់មិនបាន ។

២៤- សន ប្រធានខទពីស្រុកពញាក្រែក បច្ចុប្បន្ន រត់ទៅនៅទីព្រៃជាមួយខ្ញុំ ។

២៥- ស៊ុន អនុក្រុម បច្ចុប្បន្ននៅជាមួយខ្ញុំឯក្នុងទីព្រៃដែរ ។

២៦- ថៃ ប្រធានក្រុមក្រោយសភាពការណ៍ខ្ញុំចាប់មិនបាន ។

២៧- ថេង ប្រធានខក្រោយសភាពការណ៍ខ្ញុំចាប់មិនបាន ។

២៨ - សំ អនុប្រធានគ បច្ចុប្បន្ន ស្លាប់ហើយ ៗ

២៩ - សាយ ប្រធានខក្រោយយួនវិញខ្ញុំក្តាប់មិនបាន ៗ

៣០ - ស៊ាងហេង និសារសារ៉េន បច្ចុប្បន្ន ប្រធានតហោរទ្រៃ ៗ

៣១ - យ៉ុនបច្ចុះយុទ្ធជនចោរទ្រៃពនៅជាមួយខ្ញុំ ៗ

៣២ - សាម៉ា យុទ្ធជន បច្ចុប្បន្ន ងាប់ហើយ ៗ

៣៣ - សង្ហា យុទ្ធជន បច្ចុប្បន្ន ងាប់ហើយ ៗ

៣៤ - សួស ប្រធានឃុំឧត្តមានជ័យ បច្ចុប្បន្ន ចាប់ហើយ ៗ

៣៥ - យ៉ាន អនុឃុំឧត្តមានជ័យ បច្ចុប្បន្ន ចាប់ហើយ ៗ

៣៦ - ផ្លូន ប្រធានឃុំដូនតីខាងលិច បច្ចុប្បន្ន ចាប់ហើយ ៗ

៣៧ - មុំន អនុប្រធានឃុំដូនតីខាងលិច បច្ចុប្បន្ន ចាប់ហើយ ៗ

៣៨ - សៅ ប្រធានឃុំដូនតីខាងកើត បច្ចុប្បន្ន ចាប់ហើយ ៗ

៣៩ - យន អនុឃុំដូនតីខាងកើត បច្ចុប្បន្ន ចាប់ហើយ ៗ

៤០ - វ៉ែអម សមាជិកឃុំដូនតីខាងកើត បច្ចុប្បន្ន ចាប់ហើយ ៗ

៤១ - ផាន បច្ចុប្បន្ន សមាជិកទី ៤ ឃុំដូនតីខាងលិចស្រុកពញាក្រែក តំបន់ ២០ ៗ

៤២ - ផា បច្ចុប្បន្ន ប្រជាជននៅភូមិទួល ឃុំដូនតីខាងលិច ស្រុកពញាក្រែក តំបន់ ២០ ៗ

៤៣ - ឯនបច្ចុះប្រធានមុកព្រួញប្រចាំនៅភូមិទ្រៃពអង្គរក្នុង ឃុំដូនតីខាងលិច ស្រុកពញាក្រែកៗ

៤៤ - ឆាយ បច្ចុះ ប្រធានមុកព្រួញប្រចាំនៅភូមិពានទ្រៃព ឃុំកណ្ដាប្រជុំស្រុកពញាក្រែក ៗ

៤៥ - ស៊ុយ បច្ចុប្បន្នប្រជាជននៅភូមិទ្រៃពអង្គរក្នុង ឃុំដូនតីខាងលិច ស្រុកពញាក្រែក ៗ

៤៦ - យ៉ាំ បច្ចុប្បន្នប្រជាជននៅភូមិពរោង ឃុំដូនតីខាងលិច ស្រុកពញាក្រែក ៗ

៤៧- សយបច្ចុះប្រធានមុនព្រួញភូមិពងរោង ឃុំដូតីខាងលិច ស្រុកពញាក្រែក ១

៤៨- យ៉ាន បច្ចុប្បន្នប្រធានមុនព្រួញប្រួតភូមិពានទ្រែជ ឃុំកណ្តាប្រជុំ ស្រុកពញាក្រែក ១

៤៩- ទូច បច្ចុប្បន្ន ប្រធានលួចសហករភូមិពានទ្រែជ ឃុំកណ្តាប្រជុំ ស្រុកពញាក្រែក ១

៥០- ស៊ុន បច្ចុប្បន្នប្រជាជននៅភូមិសុវណ្ណគុម ឃុំកណ្តាប្រជុំ ស្រុកពញាក្រែក ១

៥១- ទៃអ បច្ចុប្បន្នប្រធានខាងដំាហ្វាយសហករភូមិបុសខ្នារ ឃុំកណ្តាប្រជុំ ស្រុកពញាក្រែក ១

៥២- ចយ បច្ចុប្បន្នប្រជាជនភូមិបុសខ្នារ ឃុំកណ្តាប្រជុំ ស្រុកពញាក្រែក ១

៥៣- អាំ បច្ចុប្បន្នប្រធានសេដ្ឋកិច្ចដាំបាយនៅសហករពងរោង ឃុំដូនតីខាងលិច ១

៥៤- ធាំ បច្ចុប្បន្ន អង្គការឱយទៅធ្វើស្រែនៅឃុំកណ្តាប្រជុំស្រុកពញាក្រែក តំបន់ ២០ ១

៥៥- សារ៉ាត អ្នកកាន់គេអូរបស់ស្រុកពញាក្រែក បច្ចុប្បន្ន ងាប់ហើយ ១

៥៦- ផន បច្ចុប្បន្ន អង្គការឱយទៅធ្វើស្រែនៅក្នុងឃុំកណ្តាប្រជុំស្រុកពញាក្រែក ១

៥៧- ស៊ុន បច្ចុប្បន្ន ជាប្រធានពួកចោរព្រៃនៅព្រៃអណ្តូងព្រីង ១

៥៨- សឿន បច្ចុប្បន្ន សមាជិក គពួកចោរព្រៃ ១

៥៩- សារី បច្ចុប្បន្នធ្វើចោរព្រៃទទួលខាងទាក់ទងខ្មែរនៅក្នុងរដ្ឋអំណាច ១

៦០- ទៃអ បច្ចុប្បន្នធ្វើចោរព្រៃជាអនុរបស់សារី ១

៦១- ខន បច្ចុប្បន្ន ប្រធានខពួកចោរព្រៃ ១

៦២- [illegible] បច្ចុប្បន្ន [illegible] ពួកចោរព្រៃ ១

៦២- អ៊ុំ បច្ចុប្បន្ន ប្រធានក្រុមពួកចោរព្រៃ ១

៦៣- ឈូក បច្ចុប្បន្ន អនុប្រធានទី១ពួកចោរព្រៃ ១

៦៤- សារី បច្ចុប្បន្ន ប្រធានក្រុមទី ៣ ពួកចោរព្រៃ ១

៦៥- អយ ពុទ្ធជននៅយោធាស្រុកពញាក្រែក បច្ចុប្បន្ន ងាប់ ៧

៦៦- សារិន ពុទ្ធជននៅយោធាស្រុកកំចាយមា បច្ចុប្បន្នពុទ្ធជនចោរទីក្រុង ៧

សង្កេត៖

មនុស្សនេះខ្ញុំអនុវត្តន៍គោលការរអត់ទីវិញានទាំងស្រុង

ធ្វើនៅថ្ងៃទី ខែតុលា ឆ្នាំ ១៩៧៨

មិត្តអ្នកសួរ

ពូល.ផាលី

Y59

Yin Duong

ចម្លើយ របស់ យិន.ឌួង

ជាមេក្រុមទោរទីព្រ ក្រុក ចញ្ញោវរ្សែក

---

អំពី

ប្រវត្តិបក្សភាព សេ.អ៊ី.អា ប្រឆាំងបក្ស

ពីដើមមកដល់ រហូតថ្ងៃត្រូវអង្គការចាប់ខ្លួន

១៥.វិច្ឆិកា ទ.១៩៧៨

ខ្ញុំសុំរាយការណ៍ជូនអង្គការ

អំពីពួកវៀត និងយួនមួយចំនួន ដែលខ្ញុំបានដឹង

-------------------

ចុងខែ៨ ឆ្នាំ ១៩៧៨ ក្រោយពីបងស៊ុន មកពីកន្លែងបងស៊ីម ឯព្រៃអណ្ដូងល្ហួយ ដែលឋិតនៅខាងត្បូងលៀងខាងកើតព្រៃអណ្ដូងព្រីងចំងាយប្រហែលជាងពីគីឡូម៉ែត្រ នៅក្នុងឃុំកក់ ស្រុកពញាក្រែក តំបន់ ២០ វិញ គាត់បាននិយាយប្រាប់ពួកខ្ញុំថា : យើងឥឡូវនេះមានកំលាំងកាន់តែច្រើនហើយ ព្រោះបង ស៊ីម បានរាយការណ៍ជាមួយយួនជាប់ហើយ ហើយបាននាំកំលាំងពីខាងយួនមក-នៅក្នុងព្រៃអណ្ដូងល្ហួយ ចំនួន មួយអនុសេនាធំ ដើម្បីមកក្ដាប់សភាពការណ៍នៅក្នុងភូមិភាគបូព៌ា យើង ពិសេសពួកយួនមកនេះគឺគេមកស៊ើបការ ពីកន្លែងដែលសំខាន់ៗ គឺគេស៊ើបពីកន្លែងកងទ័ពរបស់អង្គការ ទោះនៅកន្លែងណាខ្លះ និងមានច្រើនឬតិច និងស៊ើបពីកន្លែងដាក់កាំភ្លើងធំ និងពីផ្លូវដែលនាំកងទ័ពយួនមកលាក់ខ្លួននៅក្នុងព្រៃនេះបន្ថែមទៀត ដើម្បីត្រៀមផែនការទទីបដិវត្តពីងក្រោយនៅពេលដែលយួនវាយចូលមកពីខាងក្រៅនៅរដូវប្រាំងឆ្នាំ ១៩៧៨ខាងមុខនេះ ។

ហើយពួកយួនដែលមកនេះគឺគេមកតាមបងស៊ីម តាមមុខសញ្ញាខាងលិចបន្ទាយ-២៧ ខាងកើតផ្សារក្រសាល ហើយពួកយួនគេទៅរាយការណ៍ឱ្យមេវា-នៅឯខាងដីយួនក្នុងមួយខែម្ដង តាមមុខសញ្ញា ខាងលិចបន្ទាយ២៧ នេះ ។

ហើយជាផែនការរបស់យួនគឺគេ  ចង់សំអាតគឺគេចង់វាយកភូមិភាគបូព៌ា ធ្វើជាមូលដ្ឋា
ន  បង្កើតនិងសំអាតមូលដ្ឋានសេដ្ឋកិច្ច  ហើយយួនគេថាបើ ចង់វាយកភូមិភាគណាក៏
បាន គឺចង់វាយកភូមិភាគណាទៀតក៏បានដែរ  ព្រោះជាគន្លឹះគឺភូមិភាគបូព៌ា ។
ហើយចំពោះពួកយួនដែលគេមកនៅនេះ គឺគេមានស្បៀងរបស់គេក្នុងម្នាក់ៗមួយ
រ៉ាល់ទ្យ  និងមានកាំភ្លើង អាកា រ ប៤០ និងអឹម ៧៩  ដើម្បីការពារជាមួយ
យើង  អ្នកទទួលខុសត្រូវយួនគឺឈ្មោះអា ថាញ់ប្រធានអនុសេនាធំ និងអាហុងអនុ ។
ហើយយើងមិនមែនតែម្នាក់ឯង នៅទីនេះទេ  គឺយើងមានពួកយើងមួយចំនួនទៀ
ត  ដែលនៅក្នុងព្រៃណាក់ខ្លា ខាងកើតស្រុកកំចាយមារ ចំនួន ៣០០ នាក់ -
ទៀត  ហើយមានឈ្មោះ ឃន ទទួលរួមនៅទីនោះ  ឃន នេះពីមុនជាប្រ
ធានវប្បធម៌ស្រុកកំចាយមារ ។
និងឈ្មោះ ជីម អនុបងឃន  ពីមុនជាគណៈចាត់តាំងរបស់ស្រុកកំចាយមារ ។
ហើយពួកនៅក្នុងស្រុកកំចាយមារនេះ  គឺបងស៊ិម  ចាត់បានទៅទាក់ទងជាប់រហូត
មិនដែលដាច់ទេ  ដូច្នេះយើងត្រូវធ្វើយ៉ាងណា  ទំលាក់ក្លាឱ្យបាន  ហើយប្រយ័ត្ន
ខាងកងទ័ពរបស់ភូមិភាគកណ្ដាលចាប់បាន ។
ព្រោះផែនការយើងលើកនេះគឺយើងមុកជាឈ្នះហើយ  ព្រោះយួនគេហ៊ានឱ្យ
កំលាំងកងស៊ើបការគេមកបញ្ឆិតហើយ  ហើយតទៅនេះយើងចាញ់តែពេលណា
ដែលកងទ័ពរបស់អង្គការដេញម្ដងពុំទេ  តែរួចពីដេញហើយយើងឈ្នះវិញ ហើយ
ក្រោយពីបងស៊ុន  និយាយចប់ហើយក៏បែកគ្នាវិញអស់ទៅ ។

ដល់ខែ៩ ឆ្នាំ ១៩៧៨ បងស៊ីម បានហៅខ្ញុំ និង មិត្តស៊ូ យុទ្ធជន និងមិត្ត សៀក យុទ្ធជន ទៅកន្លែងគាត់ ។ ពេលទៅដល់បងស៊ីម និយាយថា ខ្ញុំឲ្យមិត្តមកនេះគឺខ្ញុំឲ្យមិត្ត ឯង ទៅជួយយាមផ្លូវ ដើម្បីឲ្យយួនគេទៅ វាយការណ៍ឲ្យមេគេនៅខាងក្រៅ ដើម្បី ឲ្យមេគេរៀបចំផែនការថ្មី កម្ពុជា យើង នៅក្នុងខែ១១ ឬ ១២ និង នៅរដូវប្រាំងឆ្នាំ៧៨ នេះ ។ ចំពោះពួកយួនដែលទៅនេះគឺគេកំណត់ពេលមួយខែ ឲ្យទៅវាយការណ៍ឲ្យ- មេគេ ហើយគេទៅនេះគឺគេទៅតែមួយខែទេគេនឹងមកវិញហើយ តែបើមាន ការលំបាកនៅតាមផ្លូវ គឺក្នុងរយៈពេលពីរខែទៀតគេត្រូវតែមកវិញ ហើយបើសភាព ការណ៍ល្អទេគឺ គេត្រូវយកកងទ័ពមកបន្ថែមទៀត ដើម្បីរៀបចំវ៉ៃនៅរដូវប្រាំង ។ ដូច្នេះមិត្តឯងត្រូវជូនគេទៅ ឲ្យបានស្រួលបួលផង ព្រោះដំណើរយើងគឺទៅឆ្ងាយផង ព្រោះផ្លូវជិតដែលយើងធ្លាប់ចេញចូល នោះគឺបែកការណ៍ហើយ ដោយពីថ្ងៃមុននេះ នៅពេលដែលយើងទៅវាយការណ៍ ក៏ត្រូវជុះមីន ហើយយើងបែកការណ៍ទៅមិនរួច ទើបខ្ញុំនិង អាថាញ់ បានពិភាក្សាគ្នាថាត្រូវតែទៅវាយការណ៍ ព្រោះផែនការ យើងជិតដល់ហើយ ហើយបើយើងវាយការណ៍ទៅតាមគេអត់ បើកងទ័ពអង្គការចាប់- គេអត់ បានយើងរកកន្លែងនៅលែងបានទៀតហើយ ព្រោះបើគេញ គេរុកព្រៃរក- ហើយ ព្រោះគេញ ពួនចាក់ចងពី ក្នុងដីខ្មែរទៅដីយួន ។ ឯបញ្ហាដែលយើងទៅ- ស៊ើបតាមផ្លូវថ្មីមួយទៀតនោះ គឺ ខ្ញុំបានឲ្យ មិត្តរុនជានិរសាខ្ញុំ ពីមុន រុននេះនៅខាង ទ្រុងទ្រឹង របស់ភូមិភាគបូព៌ា ។និងពួនពីនាក់ទៀតទៅស៊ើបការរកផ្លូវពីយើងចាក់ទៅ ខាងតំបន់ ២១ គឺបំដៅទៅទីព្រៃ ភាងុយ និងទៅទីព្រៃហោងបានហើយ ។

ដូច្នេះ មិត្តឯងទៅនេះគឺ គ្រាន់តែឃាម ផ្លូវឱ្យគេ ធ្វើដំណើរទៅតែប៉ុណ្ណោះទេ ។ ក្រោយពីណែនាំ ហើយ ខ្ញុំនិងពួកខ្ញុំបីនាក់ និងនិរសាបងស៊ីម បីនាក់ មានឈ្មោះ រុន និង អ៊ិម និង ធី បានជូនយួនទាំង មួយក្រុមទៅពីទីព្រៃអណ្ដូងល្អយ ដើរកាត់ ទៅខាងលិចភូមិធ្លក ហើយឆ្លងចាក់ទៅតាមខាងកើតភូមិឬស្សីជួរ មកដល់នេះពួកខ្ញុំក៏ដើរទៅតាម មាត់ទីព្រៃកដីកប់ដៅមកផ្លូវជាតិលេខ៧ ចំខាងកើតភូមិបត់ផ្លា ខាងលិចភូមិ ស្ទឹងចំចន្លោះកណ្ដាល ។

-. ពេលទៅដល់ជិត ផ្លូវជាតិពួកខ្ញុំបានឃើញភ្លើងឡានពីមកពីខាងកើត ហើយពួកខ្ញុំពិនិត្យតាមភ្លើងឡានទៅមិនឃើញមានអីទេ ហើយមិត្ត រុនបានឱ្យ ខ្ញុំ និងពួកខ្ញុំពីនាក់ទៀត ត្រៀមចាំនៅខាង ត្បូងផ្លូវជាតិ ចំនួនពីរយម៉ែត្រ ហើយគាត់ក៏ធ្វើដំណើរទៅមុខទៀតជាមួយពួកយួន មួយក្រុមនោះបាត់ទៅ ។

ការដែលពួកខ្ញុំទាំងអស់ទៅនេះគឺបានដាក់សៀង និងផ្ទាំង ទៅដាំបាយហូបតាមផ្លូវ ។

-. អស់រយៈពេលយប់ ៥ទីថ្ងៃទើបខ្ញុំបានឃើញមិត្ត រុន និង អ៊ិម និង ធី និរសា បងស៊ីម ត្រឡប់មកវិញ ។

ពេលមកដល់កន្លែងវិញហើយ មិត្តរុនបាននិយាយប្រាប់បងស៊ីមវិញថា : ពេលដែលពួកខ្ញុំដើរកាត់ទីព្រៃភាងគុយ ទៅដល់ទីព្រៃហោង ក៏បានទៅជួបជាមួយ តាទឹក ពីមុនប្រធានខាងចក្រភាពលើរបស់ ភូមិភាគបូព៌ា បង្កប់ខ្លួននៅក្នុងទីព្រៃហោង ជាអ្នកទទួលរួមពួកចោរទីព្រៃនៅទីព្រៃហោង ។ តែមុននិងបានទាក់ទងគ្នា គឺពួក ខ្ញុំបានពិនិត្យមើលច្បាស់លាស់ ឃើញ មានផ្ទាំងជាអ្នករត់ចូលទីព្រៃដែរទើបពួកខ្ញុំហ៊ានទៅទាក់ទងគាត់។

ដំបូងតាទឹកសួរខ្ញុំថា៖ មិត្តរុនឯងទៅណាមកណា ។ ហើយខ្ញុំបានប្រាប់តាត់ថា ខ្ញុំមកពីតំបន់២០ មកទីក្រុងនេះ គឺខ្ញុំជូនពួនមក ដើម្បីឲ្យគេទៅរាយការណ៍ទៅក្រុកខា វិញ ព្រោះពួនគេមកបង្កប់ខ្លួនយកការណ៍ទៅក្នុងតំបន់២០ ។ ហើយតាត់សួរខ្ញុំថា ម៉េចក៏មិត្តរុន ឯងនាំមកតាមផ្លូវនេះវិញ តើម៉េចក៏មិនជូនទៅជ តាមនោះវិញខាងជិត ឬក៏សភាពការណ៍ទៅខាងនោះយ៉ាងម៉េចដែរ ។

-. ចំពោះសភាពការណ៍ទៅខាងតំបន់ ២០ ឥឡូវមានការតឹងតែងណាស់ទៅតាមព្រំដែន ដោយកងទ័ពអង្គការមានការល្បាតខ្លាំងណាស់ ។ ហើយក៏ខ្លួនគេ-ទៅខាងកើតដីក្រហម ហើយតាឯងធ្លាប់ដឹងភូមិណាក្រុមខាងណឹង ខ្ញុំសុំស្នើឲ្យខាងតាឯងជូនទៅផងបានទេ ។

-. ឥឡូវនេះភូមិណាក្រុមមិនដឹងយ៉ាងម៉េចទេ បើមិត្តឯងយកមកដល់ណឹង ហើយចាំខ្ញុំដោះស្រាយឲ្យ តែមិនដឹងជាយ៉ាងណាទេ ។

-. ហើយមិត្តរុនថា ចំពោះពួន ទាំងអស់នេះគឺគេធ្លាប់ស្គាល់ផ្លូវ ត្រង់នេះអស់ហើយ-ព្រោះកាលពេលចពេលដែលគេវ៉ៃពួកអាធីវ គេមកទៅក្នុងទីក្រុងណឹងម្ដងដែរ ។ ហើយខ្ញុំមិត្តរុនតាត់ថា តាត់បានសួរតាទឹក ពីរឿងដែលតាត់ចូលទីក្រុងយូរឬទើបតែចូលទេ -ហើយមានគ្នាប៉ុន្មាននាក់ដែរ ។ តាទឹក ថា តាត់ចូលទីក្រុងកាលពីផ្ទុះអាវុធមកហើយ កំលាំងដែលទៅទីនោះគឺតាត់គ្រប់គ្រង ហើយមានគ្នាចំនួន១០០ នាក់ដែរ ។ ជាមួយនេះតាទឹក បានសួរមកមិត្តរុនវិញថា ខាងណឹងមានកំលាំងប៉ុន្មានដែរ ហើយខ្ញុំសុំទាក់ទងអង្គការខាងតំបន់២០ ផង តើអង្គការខាងណឹងថាម៉េច ។

ព្រោះខ្លាច ហើយខ្ញុំមិនបានទៅទាក់ទងផ្ទាល់ទេ ដូច្នេះខ្ញុំស្នើតាមមិត្តនុនឯងផង ។ ហើយខាងតំបន់២០ ទាក់ទងប្អូនបានពីពេលណាមក ។

មិត្តនុនថា ចំពោះប្អូននេះគឺទាក់ទងបានពីខែ១៨ ឆ្នាំ ៧៨នេះគឺគេមកមួយគ តែមួយគ គេនេះមិនពេញទេ គឺគេមកមានតែពីកងតូចទេ ។ ហើយចំពោះផែនការចាំ ខ្ញុំទៅប្រាប់ខាងអង្គការតំបន់២០ ឱ្យដឹង និងឱ្យគាត់រៀបចំទាក់ទងគ្នាឡើងវិញ - ដើម្បីយើងសហការគ្នាឱ្យកំលាំងយើងកាន់តែធំថែមទៀត ។

ក្រោយពីនិយាយគ្នា ហើយមិត្តនុនបាន ផ្ញើប្អូនឱ្យទៅតាទឹក ហើយគាត់ក៏មកវិញមក ។

-. ក្រោយមកបងស៊ឹម បានឱ្យនិរសាគាត់មកទាក់ទងជាមួយតាទឹកម្តងទៀតដើម្បី សួរពីរឿងដែល ប្អូនទៅនោះតើយ៉ាងម៉េចហើយ និងសួរពីសភាពការណ៍នៅតំបន់- ២១ ដើម្បីរៀបចំការទាក់ទងគ្នា ក្រោយពីនិរសាគាត់ចាំងបីនាក់ទៅបាត់ អស់រយៈពេល ៣ថ្ងៃនិរសាបងស៊ឹម ក៏មកដល់វិញ ។ ហើយប្រាប់បងស៊ឹមថា ចំពោះប្អូន ដែលទៅនោះមិនទាន់អស់ទេ គឺតាទឹក គាត់បានឱ្យនិរសាគាត់ ម្នាក់ ជូនប្អូន បីនាក់ទៅ តែបាត់ឃ្លូហើយគឺអស់រយៈ១១ ថ្ងៃហើយ តែមិនដឹងជាយ៉ាងណាទេ ហើយក្នុង ការដែលទៅនេះគឺ គាត់បានឱ្យនិរសាគាត់ជូនទៅតាមច្រក ភ្នំតាកុក តាម ផ្លូវ មេមុត តែដល់ឡូវនេះបាត់មិនឃើញដំណឹងសោះ មិនដឹងយ៉ាងម៉េចទេ ហើយ ពួក ប្អូន៧ នាក់ទៀតគឺនៅជាមួយកងទ័ពខ្មែររបស់តាទឹក ។ ឯចំពោះការដែលត្រូវលបកា ទាក់ទងគ្នាគឺ គាត់ប្អូនស្នើយើងទាក់ទងហើយ មិនមែនអីទេ ។

ចំពោះពួកប្អូនដែលមកនៅក្នុងព្រៃស្លុងក្រពើង នេះគឺទូតមកដល់ ៨ឆ្នាំ ១០ បច្ចុប្បន្ននេះ ។

ដែតចំពោះពួកប្អូនមួយក្រុមទៀតដែលចេញទៅ ទាហាន ទណ្ឌិយមេចាំ នោះគឺទៅបាត់

ទូតមិនឃើញមានដំណឹងអ្វីទូតមកដល់បច្ចុប្បន្ន ។

ធ្វើនៅថ្ងៃទី ១៥ វិច្ឆិកា ១៩៧៨

ហត្ថលេខា :

ផិន . ឡុង

មិត្តអ្នកសួរ

ពូលផាលី